00324547

D130/5

សម្ងាត់
CONFIDENTIAL
CONFIDENTIEL

នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត
នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

| | |
|---|---|
| សំណុំរឿងលេខ: | ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស |
| ដាក់ទៅ: | សហចៅក្រមស៊ើបអង្កេត |
| ថ្ងៃដាក់: | ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០០៩ |
| ភាគីអ្នកដាក់: | ការិយាល័យសហព្រះរាជអាជ្ញា |
| ភាសាដើម: | អង់គ្លេស |
| ប្រភេទឯកសារដែលស្នើឡើង: | សាធារណៈ |

សម្ងាត់
CONFIDENTIAL
CONFIDENTIEL

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 30/04/2009
ម៉ោង (Time/Heure): 15:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. Fuy

## ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងសំណើរបស់មេធាវី អៀង ធីរិទ្ធ ដែលស្នើសុំឲ្យបដិសេធភស្តុតាងដែលបានមកដោយសារការធ្វើទារុណកម្ម ចុះថ្ងៃទី ១១ ខែកុម្ភៈ ឆ្នាំ២០០៩

**អ្នកដាក់ឯកសារ:**
ការិយាល័យសហព្រះរាជអាជ្ញា:
លោកស្រី ជា លាង
លោក Robert PETIT
លោក យ៉ែត ចរិយា
លោក William SMITH
លោក សេង ប៊ុនឃាង
លោក Vincent de WILDE d'ESTMAEL

**អ្នកទទួលឯកសារ:**
សហចៅក្រមស៊ើបអង្កេត:
លោក យូ ប៊ុនឡេង
លោក Marcel LEMONDE

មេធាវីរបស់ជនជាប់ចោទ
ឈ្មោះ អៀង ធីរិទ្ធ:
លោក ផាត់ ពៅសៀង
លោកស្រី Diana ELLIS

សហមេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណី:
លោក ហុង គីមសួន
លោក ឡោ ជុនធី
លោក នី ចាន់ឌី
លោក គង់ ពិសី
លោកស្រី Silke STUDZINSKY
លោក យុង ផានិត
លោក គីម ម៉េងឃី
លោកស្រី Martine JACQUIN
កញ្ញា ម៉ុច សុវណ្ណារី
លោក Phillip CANNONE
លោក Pierre-Olivier SUR
លោកស្រី E. RABESANDRATANA
លោក Olivier BAHOUGNE
លោក David BLACKMAN

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 07/05/2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: UCH ARUN

## ១. សេចក្តីផ្តើម និងសេចក្តីសង្ខេបនៃអំណះអំណាង

១. មេធាវីការពារក្តីរបស់ អៀង ធីរិទ្ធ ("មេធាវីការពារក្តី") បានដាក់សំណើទាក់ទងនឹងការស៊ើបសួរមួយដែលមានចំណងជើងថា *សំណើរបស់មេធាវីការពារក្តីសុំបដិសេធភស្តុតាងដែលបានមកដោយសារការធ្វើទារុណកម្ម* ("សំណើរបស់មេធាវីការពារក្តី") ជូនទៅការិយាល័យសហចៅក្រមស៊ើបអង្កេត ("ក.ស.ច.ស") កាលពីថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៩[1] អនុលោមតាមវិធាន៥៥.១០ នៃវិធានផ្ទៃក្នុង។ តាមរយៈនេះ សហព្រះរាជអាជ្ញាស្នើដល់ ក.ស.ច.ស បដិសេធចោលនូវសំណើរបស់មេធាវីការពារក្តីនេះទាំងស្រុង ។

២. មេធាវីការពារក្តី បានស្នើសុំ ក.ស.ច.ស ឱ្យដកចេញពីសំណុំរឿងលេខ ០០២ និង មិនឱ្យពិនិត្យពិចារណាលើភស្តុតាងណាមួយដែលទាក់ទងទៅនឹងទារុណកម្ម អនុលោមតាមវិធានស្តីពីការបដិសេធភស្តុតាង ដែលចែងនៅក្នុងមាត្រា១៥ នៃអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីការប្រឆាំងនឹងការធ្វើទារុណកម្ម ("CAT") ដែលរារាំងមិនឱ្យប្រើប្រាស់នូវភស្តុតាងដែលបានមកតាមរយៈការធ្វើទារុណកម្ម នៅក្នុងការចោទប្រកាន់ក្នុងករណីរឿងក្តីព្រហ្មទណ្ឌ។ សនិទានភាពសម្រាប់វិធានស្តីពីការបដិសេធភស្តុតាងនៃអនុសញ្ញា CAT នោះគឺដើម្បី៖ (១) បញ្ឈប់ការលើកទឹកចិត្តនៃការធ្វើទារុណកម្ម ដោយហាមឃាត់ចំពោះរដ្ឋទាំងឡាយមិនឱ្យប្រើប្រាស់នូវភស្តុតាងអំពីពិរុទ្ធភាពដែលប្រមូលបានមកតាមរយៈការធ្វើទារុណកម្ម ដើម្បីប្រឆាំងនឹងជនសង្ស័យទាំងឡាយនៅក្នុងករណីព្រហ្មទណ្ឌ និង (២) ដើម្បីកាត់បន្ថយនូវលទ្ធភាពដែលអាចកើតមានស្តីពីការយកចម្លើយសារភាពណាមួយ ដែលមិនអាចឱ្យជឿទុកចិត្តបានមកប្រើប្រាស់ដើម្បីប្រឆាំងនឹងជនសង្ស័យនៅក្នុងករណីព្រហ្មទណ្ឌ[2] ។

---

[1] សំណើរបស់មេធាវីការពារក្តីស្នើសុំបដិសេធភស្តុតាងដែលបានមកដោយសារការធ្វើទារុណកម្ម, ១១ កុម្ភៈ ២០០៩, D130, ERN 00280991-00281010 (ភាសាខ្មែរ), ERN 00281011-25 (ភាសាអង់គ្លេស) [ចាប់ពីនេះតទៅហៅថា៖ "សំណើរបស់មេធាវីការពារក្តី"] ។

[2] មហាសន្និបាតអង្គការសហប្រជាជាតិ, ការធ្វើទារុណកម្ម និងការប្រព្រឹត្តិ ឬការដាក់ទណ្ឌកម្មដែលឃោរឃៅ អមនុស្សធម៌ ឬមានលក្ខណៈបន្ទាបបន្ថោកដទៃទៀត, U.N. Doc. No. A/61/259, ថ្ងៃទី១៤ សីហា ២០០៦, កថាខ័ណ្ឌទី៤៥, អាចរកបានតាមវិបសាយ

៣. សហព្រះរាជអាជ្ញាយល់ស្របតាមសន្និទានភាពនេះ។ ប៉ុន្តែមេធាវីការពារក្តីបានយល់ខុសក្នុងការអនុវត្តនូវសន្និទានភាពនេះ ដោយខកខានមិនបានយកមកពិចារណាអំពីអង្គហេតុជាក់ស្តែងចំពោះមុខនេះ។ ជាងនេះទៅទៀត សំណើរបស់មេធាវីការពារក្តីគឺមិនត្រឹមត្រូវទេ ដោយសារសំណើនោះបានប្រមូលផ្តុំនូវភស្តុតាងទាំងអស់ ដែលទាក់ទងនឹងការធ្វើទារុណកម្ម យកមកដាក់នៅក្នុងសំណុំរឿងជាមួយគ្នា ហើយខកខានមិនបានពិនិត្យទៅលើប្រភេទនីមួយៗនៃភស្តុតាង ហើយគោលបំណងសម្រាប់ភស្តុតាងនីមួយៗត្រូវបានផ្តល់ឱ្យរួចហើយ។ បន្ថែមពីលើនេះ មេធាវីការពារក្តី បានយល់ខុស និងបកស្រាយខុស អំពីគោលបំណង និងសន្និទានភាពដែលស្ថិតនៅពីក្រោយអនុសញ្ញាCATនិងវិធានស្តីពីការបដិសេធភស្តុតាងរបស់អនុសញ្ញានេះ។

៤. ក្នុងសំណុំរឿងលេខ ០០២ មានចម្លើយសារភាព និងចម្លើយជាច្រើនដែលបានធ្វើឡើងដោយអ្នកទោសនានានៃមន្ទីរស-២១ ដែលត្រូវបានរៀបចំឯកសារដោយមន្ត្រីផ្លូវការរបស់កម្ពុជាប្រជាធិបតេយ្យ ("DK") ដែលបានសួរចម្លើយ និងធ្វើទារុណកម្មទៅលើពួកគេ ។ បក្សកុម្មុយនីស្តកម្ពុជា ("ប.ក.ក") បានប្រើប្រាស់មន្ទីរស-២១ ដើម្បីអនុវត្តនូវគោលនយោបាយរបស់ ប.ក.ក ក្នុងការចាប់ខ្លួន, ការសួរចម្លើយ ការធ្វើទារុណកម្ម និងការប្រហារជីវិត ជនទាំងឡាយណាដែលត្រូវបានគេជឿថា ជាពួកខ្មាំងរបស់បក្ស ឬ ជាភ្នាក់ងារសម្ងាត់សម្រាប់ធ្វើវិទ្ធង្សនាដែលបានគម្រាមកំហែងដល់ផែនការផ្សេងៗ ឬដល់អត្ថិភាពរបស់បក្ស។ កាន់តែច្បាស់ជាងនេះទៅទៀត ភស្តុតាងនៅក្នុងសំណុំរឿងលេខ ០០២ នេះរួមមាន៖ (១) ចំណារនៅលើចម្លើយសារភាពនានា ដោយជនជាប់ឃុំឃាំងដែលត្រូវបានគេធ្វើទារុណកម្ម ទាក់ទងទៅនឹងឋានានុក្រម និងគោលនយោបាយរបស់ ប.ក.ក និង ការផ្តល់មតិរបស់អ្នកជំនាញស្តីពីមន្ទីរស-២១ ដោយផ្អែកលើចម្លើយទាំងនេះ។ (២) ចំណារនៅលើចម្លើយសារភាពដោយបុគ្គលិករបស់មន្ទីរស-២១ (៣) ព័ត៌មានពីប្រវត្តិរូបដែលបានមកនៅពេលចុះឈ្មោះនៅក្នុងបញ្ជីមន្ទីរស-២១ ។ ដូចដែលមានការពន្យល់ខាងក្រោមនេះស្រាប់ ប្រភេទនៃភស្តុតាងទាំងនេះ គួរតែត្រូវបានទទួលយក និងដែលអាចឱ្យជឿទុកចិត្តបាន ។

---

http://www.icj.org/IMG/NowakGAReport2006.pdf [ចាប់ពីនេះតទៅហៅថា៖ "របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីការធ្វើទារុណកម្ម"] ។

## ២. អំពីបញ្ញត្តិច្បាប់ជាធរមានដែលពាក់ព័ន្ធ

### ក. វិធានផ្ទៃក្នុងសម្រាប់ អ.វ.ត.ក

៥. វិធាន ៨៧.១ នៃវិធានផ្ទៃក្នុងចែងថា “លើកលែងតែមានបទប្បញ្ញត្តិផ្សេងនៅក្នុងវិធានផ្ទៃក្នុងនេះ រាល់ភស្តុតាងទាំងអស់ត្រូវតែទទួលយក” ។ តាមវិធាន ៨៧.៤ អង្គជំនុំជម្រះ “អាចកោះហៅ ឬស្តាប់ចម្លើយបុគ្គលណាម្នាក់ក្នុងនាមជាសាក្សី ឬ ទទួលយកនូវភស្តុតាងថ្មី ដែលមានប្រយោជន៍សម្រាប់ស្វែងរកការពិត”[3] ។

### ខ. ច្បាប់កម្ពុជា

៦. ច្បាប់របស់កម្ពុជា ដែលត្រូវបានលើកយកមកសំអាងដោយមេធាវីការពារក្តីបានគាំទ្រចំពោះសញ្ញាណដែលហាមឃាត់ចំពោះការប្រើប្រាស់ភស្តុតាងនេះ ដោយផ្តោតទៅលើការយកភស្តុតាងនេះទៅប្រើដើម្បីប្រឆាំងនឹងជនរងគ្រោះដោយអំពើទារុណកម្ម ។ មាត្រា៣៨ នៃរដ្ឋធម្មនុញ្ញកម្ពុជា បដិសេធនូវចម្លើយសារភាពទាំងឡាយណាដែលជា “ភស្តុតាងអំពីពិរុទ្ធភាព” និងបានកត់សំគាល់ថា វិមតិសង្ស័យណាមួយត្រូវបានដោះស្រាយដើម្បីជាប្រយោជន៍ដល់ “ជនជាប់ចោទ” ឧទាហរណ៍ដូចជា ដល់ជនរងគ្រោះដោយអំពើទារុណកម្ម ។ លើសពីនេះទៀត មាត្រានេះបានចែងបន្ថែមទៀតថា “ច្បាប់ធានាថាមិនឲ្យមានការរំលោភបំពានខាងផ្លូវកាយប្រឆាំងចំពោះបុគ្គលណាម្នាក់ឡើយ ។ ការបង្ខិតបង្ខំ ការធ្វើបាបលើរូបរាងកាយ ឬប្រព្រឹត្តកម្មដែលមិនត្រឹមត្រូវណាមួយផ្សេងទៀត ដែលជាការដាក់ទណ្ឌកម្មបន្ថែមទៀតទៅលើជនជាប់ឃុំ

---

[3] មានតែវិធាន ២១.៣ នៃវិធានផ្ទៃក្នុងប៉ុណ្ណោះដែលចែងទាក់ទងទៅនឹងបញ្ហាភស្តុតាងដែលត្រូវបានប្រឡាក់ប្រឡូសជាសក្ខានុពលទៅដោយការបង្ខិតបង្ខំ ក៏វិធាននោះអនុវត្តបានចំពោះតែការបង្ខិតបង្ខំណាដែលកើតឡើងដោយសារភ្នាក់ងាររបស់ អ.វ.ត.ក ផ្ទាល់តែប៉ុណ្ណោះ ។

ឬអ្នកទោសណាម្នាក់ត្រូវហាមឃាត់"[4]។ មាត្រា៣២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាបានផ្តោតស្រដៀងគ្នានេះដែរ ទៅលើចម្លើយសារភាពអំពីពិរុទ្ធភាពដែលធ្វើឡើងដោយជនជាប់ឃុំដែលបានមកដោយសារការបង្ខិតបង្ខំខាងផ្លូវកាយ ឬខាងផ្លូវបញ្ញាស្មារតី ។

**គ. អនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម** ("CAT")

៧. ការហាមឃាត់ចំពោះការធ្វើទារុណកម្ម គឺជាបទដ្ឋាននៃច្បាប់អន្តរជាតិដែលតម្រូវឱ្យរដ្ឋនានាត្រូវជាប់កាតព្វកិច្ចអនុវត្តតាម (*jus cogens norms*) និងដែលឆ្លុះបញ្ចាំងយ៉ាងច្បាស់នៅក្នុងអនុសញ្ញា CAT ដែលប្រទេសកម្ពុជាបានទទួលយល់ព្រមអនុវត្តតាមនោះ គឺត្រូវលុបបំបាត់ចោលនូវការប្រើទារុណកម្ម ត្រូវតែធានាថា ការធ្វើទារុណកម្មត្រូវតែបានទប់ស្កាត់ ហើយការខកខានក្នុងការទប់ស្កាត់គឺត្រូវទទួលការផ្តន្ទាទោស[5] ។ មាត្រា៦ នៃអនុសញ្ញា CAT ចែងថា នៅទីកន្លែងណាក៏ដោយ ដែលអ្នកធ្វើទារុណកម្មណាម្នាក់មានវត្តមាននៅក្នុងរដ្ឋដែលជាភាគីណាមួយ គឺរដ្ឋនោះ "ត្រូវយកជននោះទៅដាក់នៅកន្លែងឃុំឃាំង" ។ មាត្រា១២ ណែនាំឱ្យរដ្ឋជាភាគីណាមួយ ត្រូវធ្វើការស៊ើបអង្កេតលើការចោទប្រកាន់នានាអំពីការធ្វើទារុណកម្ម ។ មាត្រា១៤ កំណត់អាណត្តិឱ្យជនរងគ្រោះទាំងឡាយដោយសារអំពើទារុណកម្ម មានសិទ្ធិស្វែងរកយុត្តិធម៌តាមផ្លូវរដ្ឋប្បវេណីប្រឆាំងនឹងជនទាំងឡាយណា ដែលបានធ្វើទារុណកម្មលើជនរងគ្រោះទាំងនោះ *ជាដើម* ។ល។

៨. មាត្រា ១៥ នៃវិធានស្តីពីការបដិសេធភស្តុតាងត្រូវតែយល់ឃើញឱ្យបានស្របទៅតាមបរិបទទាំងមូលនៃគោលបំណងរបស់អនុសញ្ញា CAT។ មាត្រា១៥ ចែងថា "រដ្ឋដែលជាភាគីនីមួយៗត្រូវតែធានាឱ្យបានប្រាកដប្រជាថា ចម្លើយណាមួយដែលមានសក្ខីកម្មបង្ហាញថាបានធ្វើឡើងដោយសារលទ្ធផលនៃការធ្វើទារុណកម្មណាមួយនោះ គឺមិនអាចយកមកធ្វើជាភស្តុតាងនៅ

---

[4] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា (ឆ្នាំ ១៩៩៣), មាត្រា ៣៨, *អាចរកបានតាមវែបសាយ* http://www.embassy.org/Cambodia/government/constitution.htm. ។

[5] អនុសញ្ញាអន្តរជាតិស្តីពីការប្រឆាំងនឹងការធ្វើទារុណកម្ម និងការប្រព្រឹត្តិមកលើខ្លួន ឬទណ្ឌកម្មដទៃទៀតដែលឃោរឃៅអមនុស្សធម៌ ឬបន្ថោកបន្ទាប, G.A. Res. 39/46, U.N. GAOR, 39th Sess., Supp. No. 51, U.N. Doc. A/39/51 (1984), មាត្រា ៤-៩, ១៤ [ចាប់ពីនេះតទៅហៅថា៖ "អនុសញ្ញា CAT"] ។

ក្នុងដំណើរការនៃនីតិវិធីណាមួយបានឡើយ លើកលែងតែប្រើដើម្បីប្រឆាំងនឹងជនដែលត្រូវចោទប្រកាន់ពីការធ្វើទារុណកម្ម ដើម្បីធ្វើជាភស្តុតាងថា ចម្លើយនោះគឺត្រូវបានធ្វើឡើងដោយសារការធ្វើទារុណកម្មតែប៉ុណ្ណោះ"[6] ។

៩. តាមអ្នករាយការណ៍ពិសេសស្តីពីការធ្វើទារុណកម្ម សនិទានភាពដែលស្ថិតនៅពីក្រោយមាត្រា ១៥ នោះមានពីរយ៉ាងគឺ: (១) ហាមឃាត់ការប្រើប្រាស់ភស្តុតាងនេះ ដើម្បីជៀសវាងការលើកទឹកចិត្តដល់ការប្រើទារុណកម្ម និង (២) ព័ត៌មានណាដែលបានមកតាមរយៈការធ្វើទារុណកម្មជាទូទៅគឺមិនត្រូវចាត់ទុកថា គួរឱ្យជឿបានដើម្បីប្រើប្រាស់នៅក្នុងដំណើការនីតិវិធីរបស់តុលាការនោះទេ[7] ។

១០. ដោយពុំមានលទ្ធភាពក្នុងការយកមកប្រើប្រាស់ នូវចម្លើយសារភាពអំពីពិរុទ្ធភាពដែលបានមកដោយបង្ខំសម្រាប់ប្រឆាំងនឹងបុគ្គលនានានោះ ទារុណកម្មមុខជានឹងលែងសូវមានប្រយោជន៍ចំពោះរដ្ឋណាមួយដែលគិតគូរពីការប្រើវាទៀតហើយ ។ Tobias Thienel ដែលមេធាវីការពារក្តីបានពឹងផ្អែកយ៉ាងខ្លាំងទៅលើគាត់នោះ បានបង្ហាញអត្តសញ្ញាណឱ្យដឹងថា ក្នុង "ករណីរឿងជាគំរូយ៉ាង" ដែលក្នុងនោះរដ្ឋដែលតុលាការយកករណីរឿងក្តីមកដោះស្រាយគឺជាចារី ហើយជនរងគ្រោះដោយអំពើទារុណកម្មគឺជាភាគីនៅក្នុងនោះ ដែលត្រូវបានគេលើកយកភស្តុតាងមកប្រឆាំងនឹងគាត់ថា "*គឺជាអ្នកដែលរំលោភទៅលើអំណាចរបស់រដ្ឋ តាមមាត្រា១៥ នៃអនុសញ្ញា CAT របស់អង្គការសហប្រជាជាតិ ដែលមានបំណងសំខាន់ចង់ដាក់ឱ្យស្ថិតនៅក្រៅច្បាប់*"[8] ។ ស្រដៀងគ្នានេះដែរ អាចត្រូវបានលើកឡើងជំទាស់ថា ការព្រួយបារម្ភអំពីភាពដែលអាចជឿទុកចិត្តបាន - ដែលគេមិនអាចដឹងថា តើចម្លើយសារភាពបានមកតាមរយៈការធ្វើទារុណកម្ម បានឆ្លុះបញ្ចាំងឱ្យឃើញការពិតដែរឬទេ ឬមួយគ្រាន់តែជាចម្លើយមួយដែលធ្វើឡើងដើម្បីឱ្យបញ្ឈប់ការធ្វើទារុណកម្មនោះ-ត្រូវបានធ្វើថយចុះជាអប្បបរិមា បើសិនជាចម្លើយ

---

[6] អនុសញ្ញា CAT, មាត្រា ១៥ ។

[7] របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីការធ្វើទារុណកម្ម, ត្រង់កថាខ័ណ្ឌទី៤៥ ។

[8] Tobias Thienel, "*ការទទួលយកបាននូវភស្តុតាងដែលបានមកដោយសារការធ្វើទារុណកម្ម តាមច្បាប់អន្តរជាតិ*", 17 E.J.I.L. 349 (2006), at 356 [សង្កត់ន័យបន្ថែមដោយ *អក្សរទ្រេត*] [ចាប់ពីនេះតទៅហៅថា៖ "Thienel"] ។

ដែលបានលើកឡើងទាំងនោះមិនមែនជាចម្លើយសារភាពពីអំពើដែលជា"បទព្រហ្មទណ្ឌនោះទេ ប៉ុន្តែជាចម្លើយដែលសេរីៗ ឬដែលជាប្រវត្តិដើមទៅវិញ ។

១១. របាយការណ៍របស់គណៈកម្មាធិការប្រឆាំងនឹងទារុណកម្ម ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០០៣ ដែលត្រូវបានលើកយកមកសំអាងដោយមេធាវីការពារក្តី បានឆ្លុះបញ្ចាំងឱ្យឃើញពីការយល់ដឹងអំពីវិធានស្តីពីការបដិសេធភស្តុតាងនេះ ។ អនុសាសន៍ជាច្រើនដែលត្រូវបានលើកឡើងជូនដល់ប្រទេសកម្ពុជាថា សុំឱ្យប្រទេសនេះបដិសេធភស្តុតាង ដែលបានមកតាមរយៈការធ្វើទារុណកម្ម ដោយផ្អែកទៅលើអង្គហេតុជាក់ស្តែងដែលថា នគរបាល និងតុលាការរបស់កម្ពុជាបានពឹងផ្អែកយ៉ាងខ្លាំងទៅ *លើចម្លើយសារភាពដើម្បីប្រឆាំងនឹងជនទាំងឡាយដែលត្រូវគេធ្វើទារុណកម្មសម្រាប់ធានាឱ្យប្រាកដអំពីភាពដែលត្រូវមានទោស*[9] ។

១២. ស្រដៀងគ្នានេះ របាយការណ៍របស់អង្គការ Redress ឆ្នាំ២០០៥ ទាក់ទងទៅនឹងការប្រើចម្លើយសារភាពដែលបានមកតាមរយៈការធ្វើទារុណកម្ម ដើម្បីប្រឆាំងនឹងបុគ្គលដដែលដែលត្រូវគេធ្វើទារុណកម្ម ។ របាយការណ៍នេះបានកត់សំគាល់ថា ការប្រើទារុណកម្ម "គ្រាន់តែជាការលើកទឹកចិត្តដល់បច្ចេកទេសសួរចម្លើយតែប៉ុណ្ណោះ ដែលជាលទ្ធផលនាំឱ្យមានការធ្វើទារុណកម្ម" និងលើកអនុសាសន៍ថា រដ្ឋទាំងឡាយគួរតែចាត់វិធានការណ៍ដើម្បីកាត់បន្ថយអំពីភាវនីយភាពនៃការប្រើប្រាស់ទារុណកម្ម "ដើម្បីបង្ខិតបង្ខំឱ្យផ្តល់ចម្លើយសារភាព ឬចម្លើយផ្សេងៗ ដូចជាតម្រូវថា ចម្លើយសារភាពអាចផ្តល់ឱ្យបានតែចំពោះមន្ត្រីណាម្នាក់ដែលមានបណ្តាសក្តិចាប់ពីថ្នាក់ណាមួយឡើងទៅប៉ុណ្ណោះ" និងទទួលស្គាល់ថា *ជនជាប់ឃុំខ្លួន*ត្រូវតែបានគេប្រាប់ឱ្យដឹងអំពីសិទ្ធិធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង[10] ។

---

[9] គណៈកម្មាធិការប្រឆាំងនឹងការធ្វើទារុណកម្ម, សេចក្តីសន្និដ្ឋាន និងអនុសាសន៍ របស់គណៈកម្មាធិការប្រឆាំងនឹងការធ្វើទារុណកម្ម, កម្ពុជា, ថ្ងៃទី២៧ ឧសភា ២០០៣, Doc. No. CAT/C/CR/30/2 (ដោយមានការសន្និដ្ឋានទៅលើការសង្កេត/ការធ្វើអត្ថាធិប្បាយ), *អាចរកបានតាមវិបសាយ* http://193.194.138.190/tbs/doc.nsf/(Symbol)/CAT.C.CR.30.2.En?OpenDocument, កថាខណ្ឌទី ៦.ជ, ៧.ខ [សង្កត់ន័យបន្ថែមដោយ *អក្សរទ្រេត*] ។

[10] អង្គការ Redress, "ការចាប់ផ្តើមនៃការហាមឃាត់ជាអន្តរជាតិទៅលើគេហដ្ឋានទារុណកម្ម៖ មគ្គុទ្ទេសក៍សម្រាប់ការអនុវត្តន៍នៅថ្នាក់ជាតិ ចំពោះអនុសញ្ញាអន្តរជាតិស្តីពីការប្រឆាំងនឹងការធ្វើទារុណកម្ម និងការប្រព្រឹត្តិមកលើខ្លួន ឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប", អង្គការ The Redress Trust: ទីក្រុងឡុង (ខែមករា ឆ្នាំ២០០៦), *អាចរកបានតាមវិបសាយ*

00324554

D130/5



១៣. ត្រូវតែគូសបញ្ជាក់ឱ្យច្បាស់ថាមាត្រា១៦ នៃអនុសញ្ញា CAT ចែងថា រដ្ឋជាភាគីនីមួយៗ "ត្រូវទទួលភារៈក្នុងការទប់ស្កាត់នូវអំពើសាហាវយង់ឃ្នង ប្រព្រឹត្តកម្មដែលអមនុស្សធម៌ ឬបន្ទាបបន្ថោកផ្សេងៗទៀត ឬការដាក់ទណ្ឌកម្ម នៅលើទឹកដីណាមួយដែលស្ថិតក្រោមដែនសមត្ថកិច្ចរបស់ខ្លួន ដែលមិនឈានទៅដល់កំរិតការធ្វើទារុណកម្មនោះទេ ដូចដែលបានចែងកំណត់នៅក្នុងមាត្រា១" និងបានធ្វើការកត់សំគាល់ដោយជាក់លាក់ថា "កាតព្វកិច្ចទាំងឡាយដូចដែលមានចែងនៅក្នុង មាត្រា១០, ១១, ១២ និង១៣ ត្រូវតែអនុវត្តដោយការដាក់ជំនួស សម្រាប់ធ្វើជាចំណុចយោងទៅលើទារុណកម្ម ឬចំណុចយោងទៅលើទម្រង់ផ្សេងៗទៀតនៃ អំពើសាហាវយង់ឃ្នង ប្រព្រឹត្តកម្មដែលអមនុស្សធម៌ ឬបន្ទាបបន្ថោកដទៃៗទៀត ឬការដាក់ទណ្ឌកម្ម" ។ ជាការគួរឱ្យកត់សំគាល់ នេះគឺជាការមិនអនុវត្តតាមមាត្រា១៥ របស់វិធានស្តីពី ការបដិសេធភស្តុតាង[11] ។

## ឃ. គោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិស្តីពី តួនាទីរបស់រដ្ឋអាជ្ញា

១៤. នៅក្នុងឆ្នាំ១៩៩០ គោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិសម្រាប់រដ្ឋអាជ្ញា ("គោលការណ៍ណែនាំ អ.ស.ប") ត្រូវបានអនុម័ត តម្រូវដល់រដ្ឋអាជ្ញាទាំងឡាយត្រូវតែ "ចាត់វិធានការណ៍ដ៏ចាំបាច់ដើម្បីធានាថា ជនទាំងឡាយដែលទទួលខុសត្រូវចំពោះការប្រើប្រាស់វិធីសាស្ត្របែបនេះ [រួមទាំងការធ្វើទារុណកម្មផង] ត្រូវតែបាននាំខ្លួនទៅកាន់តុលាការដើម្បីស្វែងរកយុត្តិធម៌"[12]។ ជាសំខាន់ អង្គការសហប្រជាជាតិបានទទួលស្គាល់ថា រដ្ឋអាជ្ញាទាំងឡាយ អាចប្រើ

---

http://www. redress.org/publications/CAT%20Implementation%20paper%2013%20Feb%202006.pdf, ទំព័រ ៦២-៦៣ ។

[11] នៅឆ្នាំ ១៩៨១ ក្រុមការងារអនុសញ្ញា CAT បានជួប និង បានព្រាងព្រៀងមិនបញ្ចូលឯកសារយោងទៅនឹងមាត្រា ១៥ ដោយពាក់ព័ន្ធនឹងមាត្រា ១៦ ។ *សូមមើល* H. Burgers and H. Danielus, *អនុសញ្ញាអន្តរជាតិស្តីពីការប្រឆាំងនឹងការធ្វើទារុណកម្ម: សៀវភៅក្បួនណែនាំអំពីអនុសញ្ញាស្តីពីការប្រឆាំងនឹងការធ្វើទារុណកម្ម និងការប្រព្រឹត្តិមកលើខ្លួន ឬទណ្ឌកម្មឯទៀតដែលឃោរឃៅអមនុស្សធម៌ ឬ បន្ថោកបន្ទាប*, Martinus Nijhoff Publishers: Dordretch (1988), ទំព័រ ៧៥ ។

[12] មហាសន្និបាតអង្គការសហប្រជាជាតិលើកទី ៨ ស្តីពីការទប់ស្កាត់អំពើទារុណកម្ម និងការប្រព្រឹត្តិទៅលើអ្នកប្រព្រឹត្តបទល្មើស: គោលការណ៍ណែនាំស្តីពីតួនាទីរបស់រដ្ឋអាជ្ញា, U.N. Doc. A/CONF, 144/28/Rev.1, Havana, Cuba, ពីថ្ងៃទី២៧ សីហា ដល់ថ្ងៃទី៧ កញ្ញា ១៩៩០, ត្រង់គោលការណ៍ណែនាំលេខ ១៦ [ចាប់ពីនេះតទៅហៅថា៖ "គោលការណ៍ណែនាំរបស់ អសប"] ។

ប្រាស់ភស្តុតាងដែលបានមកតាមរយៈការធ្វើទារុណកម្មប្រឆាំងនឹង "*ជនទាំងឡាយណាដែលប្រើប្រាស់វិធីសាស្ត្រប៉ះពាល់*" បានដោយគ្មានការកំរិត[13] ។

## ៣. អំណះអំណាង

### ក. គោលការណ៍ស្តីពីភាពអាចបត់បែនបាន អនុញ្ញាតឲ្យ អ.វ.ត.ក ទទួលយកភស្តុតាងនេះ ហើយបន្ទាប់មកទៀត ឲ្យចាត់តាំងប្រគល់នូវស្ថានទម្ងន់ត្រឹមត្រូវដល់ភស្តុតាងនិមួយៗ

១៥. អ.វ.ត.ក គួរតែអនុញ្ញាតឲ្យទទួលយកនូវភស្តុតាងទាំងឡាយដូចដែលបានគូសបញ្ជាក់ខាងលើ ហើយបន្ទាប់ពីពិនិត្យឡើងវិញរួច ចាត់តាំងផ្តល់ភស្តុតាងនីមួយៗ នូវស្ថានទម្ងន់ត្រឹមត្រូវរបស់វា ។ នៅតុលាការ*ពិសេស*អន្តរជាតិនីមួយៗ ចាប់តាំងពីតុលាការ ICTY រហូតទៅដល់តុលាការ SCSL គឺសុទ្ធតែបានបង្កើតដោយប៉ិនប្រសប់នូវរបបស្តីពីភាពអាចបត់បែនបានមួយសម្រាប់ការទទួលយកនូវភស្តុតាង-ដែលរាប់បញ្ចូលទាំង អ.វ.ត.ក ផង[14] ។ តុលាការព្រហ្មទណ្ឌអន្តរជាតិនានាបានដាក់ចេញនូវគោលការណ៍ស្តីពីភាពអាចបត់បែនបានដើម្បីជៀសវាងកុំឲ្យវិធានស្តីពីភស្តុតាងរបស់ថ្នាក់ជាតិមានភាពស៊ាំញ៉ាំ និងស្មុគស្មាញ[15] គួរបសង្កត់នៅក្នុងយុត្តាធិការដែលមានគណៈវិនិច្ឆ័យនៅក្នុងនោះបំរើការជាគណៈវិនិច្ឆ័យលើអង្គហេតុជំនួស

---

[13] គោលការណ៍ណែនាំរបស់ អសប, លេខ ១៦ ។

[14] សូមអាន ឧទាហរណ៍ដូចជា វិធាន៨៧.៤ ដែលអនុញ្ញាតឲ្យគ្រប់ភស្តុតាងទាំងអស់ "ដែលនាំមកនូវការបង្ហាញការពិត"។

[15] សូម្បីតែនៅក្នុងប្រព័ន្ធច្បាប់អង់គ្លេសាក់សុង (common law) ដែលមានវិធាននៃភស្តុតាងយ៉ាងតឹងរ៉ឹង មិនដូចគ្នាទៅនឹងវិធាននៃភស្តុតាងដែលអាចបត់បែនបាន ដែលអនុវត្តនៅក្នុងតុលាការអន្តរជាតិនានា ក៏នៅតែមានករណីលើកលែងដោយផ្អែកលើមូលដ្ឋាននៃភាពទោល និងសារៈសំខាន់ដែរ ។ នៅ ស.រ.អា "ករណីលើកលែងដែលនៅសេសសល់" (the residual exception) ទៅនឹងការរាំងពាក្យចចាមអារ៉ាម បានអនុញ្ញាតឱ្យមានការទទួលយកនូវភស្តុតាងបាន នៅពេល៖ (ក) ចម្លើយមួយត្រូវបានគេផ្តល់ជាភស្តុតាងមានបញ្ជាក់ អំពីអង្គហេតុមួយដែលជាក់ស្តែង ។ (ខ) ចម្លើយនោះអាចបញ្ជាក់ការពិតលើចំណុចដែលត្រូវបានផ្តល់ឲ្យជាងភស្តុតាងណាៗផ្សេងទៀតដែលអ្នកគាំទ្រអាចផ្តល់ឲ្យបានតាមរយៈកិច្ចប្រឹងប្រែងដ៏សមហេតុផលមួយ ។ និង (គ) ការទទួលយកនូវចម្លើយទាំងនេះដើម្បីដាក់បញ្ចូលក្នុងភស្តុតាង និងជួយបំរើការយ៉ាងល្អប្រសើរបំផុតដល់ការសម្រេចបាននូវគោលបំណងទូទៅនៃវិធានទាំងនេះ និងដល់ផលប្រយោជន៍នៃយុត្តិធម៌ ។ *សូមមើល* វិធានសហព័ន្ធស្តីពីវិធាននៃភស្តុតាងរបស់ស.រ.អា, ត្រង់វិធាន ៨០៧, "ករណីលើកលែងដែលនៅសេសសល់" ។ នៅទីនេះ ភស្តុតាងគឺមានពាក់ព័ន្ធយ៉ាងជាក់ស្តែង ដែលមិនអាចផ្តល់ឲ្យបានតាមមធ្យោបាយណាផ្សេងទៀតទេ ហើយនឹងបំរើឲ្យផលប្រយោជន៍នៃយុត្តិធម៌ ។

ឲ្យទៅក្រុមអាជីព[16] ។ ដូចដែលតុលាការ ICTY បានធ្វើការកត់សំគាល់ថា "មុខងាររបស់តុលាការនេះ គឺមិនមែនដើម្បីធ្វើឲ្យខ្លាចរអារនិងដាក់ទណ្ឌកម្មចំពោះការប្រព្រឹត្តិខុសច្បាប់ដោយអាជ្ញាធរក្នុងស្រុកនានាដែលពង្រឹងការអនុវត្តច្បាប់ ដោយការបដិសេធនូវភស្តុតាងដែលបានមកដោយខុសច្បាប់នោះទេ"[17] ។ គួរឲ្យចាប់អារម្មណ៍នោះគឺតុលាការ ICTY និងតុលាការ ICTR បានអនុញ្ញាត *ឲ្យទទួលយក* ភស្តុតាងដែលបានមកតាមរយៈការរំលោភទៅលើបុព្វសិទ្ធិរបស់មេធាវី-កូនក្តី ឆែកឆេរដោយគ្មានដីកា និងដោយការលួចស្តាប់ការទាក់ទងគ្នាតាមទូរស័ព្ទដោយខុសច្បាប់ ឲ្យតែជនទាំងឡាយដែលប្រមូលភស្តុតាងនោះមិនមែនជានិយោជិត ឬជាភ្នាក់ងាររបស់តុលាការ[18] ។

---

[16] Gideon Boas, *ភាពអាចទទួលយកបាននៃភស្តុតាង តាមវិធាននៃនីតិវិធី និងភស្តុតាងសម្រាប់តុលាការ ICTY: ការអភិវឌ្ឍន៍នៃគោលការណ៍ស្តីពីភាពបត់បែន* នៅក្នុងសៀវភៅបទនិពន្ធខ្លីៗស្តីពីដំណើរការនីតិវិធី និងភស្តុតាងសម្រាប់តុលាការ ICTY ដើម្បីឧទ្ទិសដល់ Gabrielle Kirk McDonald, កម្រងទី៣ នៃច្បាប់មនុស្សធម៌អន្តរជាតិ លេខ២៦៣ (ឆ្នាំ២០០១), ត្រង់ ២៦៥ ។ *សូមមើល* ចៅក្រម Richard May និង Marieke Wierda, *និន្នាការនៅក្នុងភស្តុតាងព្រហ្មទណ្ឌអន្តរជាតិ: Nuremburg, Tokyo, The Hague, and Arusha,* 37 Columb. J. Transnat'l L. លេខ៧២៥ (ឆ្នាំ១៩៩៨-១៩៩៩), ត្រង់ ៧២៥: "ការអនុវត្តន៍មួយដ៏សំខាន់របស់តុលាការអន្តរជាតិទាំងអស់ គឺការបដិសេធរបស់ពួកគេ មិនព្រមឲ្យវិធីសាស្ត្របច្ចេកទេស ក្នុងការទទួលយកនូវភស្តុតាង ដឹកមុខពួកខ្លួននៅក្នុងការស្វែងរកការពិតបានឡើយ...។ នេះគឺត្រូវបានបង្ហាញឲ្យឃើញយ៉ាងល្អបំផុត តាមរយៈវិធីសាស្ត្ររបស់ខ្លួនទៅនឹងភស្តុតាងអំពីពាក្យចចាមអារ៉ាម ក៏ប៉ុន្តែវាក៏ត្រូវបានឆ្លុះបញ្ចាំងផងដែរនៅក្នុងការទទួលយកនូវឯកសារនានា និងលិខិតថ្លែងសច្ចាផ្សេងៗ ។ នៅក្នុងបញ្ហាទាំងអស់នេះ តុលាការបានអនុម័តយកនូវវិធីសាស្ត្រដែលមានលក្ខណៈសេរីមួយ តែមិនត្រូវបានគាបសង្កត់ដោយវិធាននានានៃប្រព័ន្ធច្បាប់អង់គ្លេសាក់សុង (common law) ទេ" ។

[17] *រង្វអាជ្ញា ទល់នឹង Brdjanin,* សំណុំរឿងលេខ: IT-99-36-T, សេចក្តីសម្រេចលើការជំទាស់របស់មេធាវីការពារក្តីទៅនឹងភស្តុតាងដែលបានមកដោយសារការលួចស្តាប់, ចុះថ្ងៃទី០៣ តុលា ២០០៣, (អង្គជំនុំជម្រះសាលាដំបូង), កថាខ័ណ្ឌទី៦៣.៩, *អាចរកបានតាមវិបសាយ* http://www.un.org/icty/brdjanin/trialc/decision-e/031003.htm *ដែលបានលើកឡើង* នៅក្នុង Michael P. Scharf, *"ផ្លែឈើពីដើមឈើដែលមានស្នាមប្រឡាក់: បើសិនជាមាននោះ តើនៅពេលណាទើបភស្តុតាងពាក់ព័ន្ធនឹងការធ្វើទារុណកម្មអាចត្រូវបានទទួលយក?", 65 Wash & Lee L. Rev. 129 (Winter 2008),* ត្រង់ចំណុចសំគាល់លេខ 116 [ចាប់ពីនេះតទៅហៅថា៖ "Scharf"] ។

[18] *សូមមើល* Scharf, ត្រង់ចំណុចសំគាល់លេខ 115 (ដែលប្រមូលករណីរឿងផ្សេងៗ) (ដែលរួមទាំងករណីរឿង *រង្វអាជ្ញា ទល់នឹង Brdjanin,* សំណុំរឿងលេខ IT-99-36-T, ចុះថ្ងៃទី០៣ តុលា ២០០៣, សេចក្តីសម្រេចលើការជំទាស់របស់មេធាវីការពារក្តីទៅនឹងភស្តុតាងដែលបានមកដោយការលួចស្តាប់, កថាខណ្ឌទី ៦១-៦៨, ដោយបានច្រានចោលញត្តិស្នើសុំឲ្យបដិសេធនូវភស្តុតាងរបស់ចុងចោទដែលបានមកតាមរយៈការលួចស្តាប់នូវការសន្ទនាគ្នាតាមទូរស័ព្ទដោយខុសច្បាប់ពីសំណាក់អាជ្ញាធរ ឬស្មី ដោយធ្វើការកត់សម្គាល់ថា "នៅក្នុងស្ថានការណ៍ដែលមានជម្លោះប្រដាប់អាវុធ ការស៊ើបការណ៍យកព័ត៌មានសម្ងាត់ដែលអាចជាលទ្ធផលបានមកសកម្មភាពខុសច្បាប់ អាចនឹងផ្តល់សក្ខីកម្មថា មានសារៈសំខាន់ក្នុងការលាតត្រដាងអំពីការពិត ។ ការណ៍ទាំងអស់នេះកាន់តែសំខាន់ថែមទៀត នៅពេលដែលគេមិនអាចរកព័ត៌មាននេះពីប្រភពផ្សេងទៀតបាន") ។

១៦. តាមការកត់សំគាល់ វិធានផ្ទៃក្នុងមានលក្ខណៈបត់បែនច្រើនជាងវិធានផ្ទៃក្នុងរបស់តុលាការដទៃទៀត[19] ។ ខណៈដែលតុលាការ ICTY និង ICTR បានកំរិតត្រឹមតែពិចារណាលើភស្តុតាងដែលមានការពាក់ព័ន្ធផង *និង* ដែលអាចបញ្ជាក់ការពិតបានផង- ដោយមានការថ្លឹងថ្លែងអំពីភាពអាចជឿទុកចិត្តបាននៃភស្តុតាងដែលបានដាក់បញ្ចូលនៅក្នុងការកំណត់សម្រេចអំពីថាតើអាចបញ្ជាក់ការពិតបានដែរឬទេ[20] - អ.វ.ត.ក អាចពិចារណាលើ "ភស្តុតាងណាមួយ... ដែលមានប្រយោជន៍ នៅសម្រាប់ការបញ្ជាក់អំពីការពិត" (*មានន័យថា* ភស្តុតាងណាមួយដែលពាក់ព័ន្ធ)[21] ។

១៧. វិធាន២៨ នៃវិធានផ្ទៃក្នុង "សិទ្ធិមិនធ្វើសក្ខីកម្មដែលដាក់បន្ទុកលើខ្លួនឯងរបស់សាក្សី" បានដាក់បញ្ចូលយ៉ាងច្បាស់នៅក្នុងច្បាប់គ្រប់គ្រងរបស់ អ.វ.ត.ក រួចហើយ អំពីទស្សនទាននៃការថ្លឹងថ្លែងអំពីភាពពិសេសខុសពីគេដែលមានតែមួយគត់ និងសារៈសំខាន់នៃភស្តុតាងដែលគេរំពឹងទុកប្រឆាំងនឹងគោលការណ៍ដែលបានចែងរបស់ អ.វ.ត.ក ស្តីពីការការពារចំពោះសាក្សីកុំឲ្យធ្វើសក្ខីកម្មដែលដាក់បន្ទុកលើខ្លួនឯង និងភាពស្រួចស្រាវនៃសេចក្តីត្រូវការចាំបាច់នូវភស្តុតាងរបស់តុលាការនេះ ។ ដូចវិធាន២៨ បញ្ជាក់ដោយមិនច្បាស់លាស់អំពី នៅក្នុងសេចក្តីសម្រេចថាតើក្នុងការទទួលយកភស្តុតាង ជួនកាលត្រូវឲ្យមានការគិតគូថាតើ ក.ស.ច.ស ឬអង្គជំនុំជម្រះណាមួយរបស់ អ.វ.ត.ក អាចយកភស្តុតាងពីប្រភពផ្សេងណាមួយមកជំនួសភស្តុតាងដែលកំពុងចោទសួរនេះបានដែរឬទេ ។ ភស្តុតាងដែលមាននៅក្នុងឯកសារចេញពីមន្ទីរស-២១ ផ្តល់នូវប្រភពព័ត៌មានពិសេសប្លែកពីគេ និងដ៏សំខាន់ដើម្បីជាជំនួយដល់ ក.ស.ច.ស និង អ.វ.ត.ក

[19] Scharf, ត្រង់ទំព័រទី ១៥៧ ។

[20] អវត្តមាននៃលក្ខខណ្ឌតម្រូវមួយដែលថាភស្តុតាងត្រូវតែអាចបញ្ជាក់ការពិតបានទើបអាចនឹងទទួលយកបាននោះគឺជាបញ្ហាសំខាន់។ នៅក្នុងករណី Tadic, តុលាការ ICTY បានសម្រេចថា វិធានផ្ទៃក្នុងរបស់ខ្លួនបានតម្រូវក្នុងន័យបង្កប់ថា ភស្តុតាងត្រូវតែអាចទុកចិត្តបាន - ភស្តុតាងដែល មិនអាចទុកចិត្តបាន មិនអាចបញ្ជាក់បានឡើយ និងត្រូវបានច្រានចោលក្រោមវិធាន៨៩.គ របស់ ICTY: "នៅក្នុងការវាយតម្លៃអំពីតម្លៃនៃ ភាពអាចបញ្ជាក់បាននៃភស្តុតាងចចាមអារ៉ាម អង្គជំនុំជម្រះសាលាដំបូងត្រូវតែយកចិត្តទុកដាក់ទៅលើសញ្ញាបង្ហាញនៃភាពអាចទុកចិត្តបាន ។ ដើម្បីបានដល់ការកំណត់ដូច្នេះ អង្គជំនុំជម្រះសាលាដំបូងអាចពិចារណាថាតើ សក្ខីកម្មមួយត្រូវបានធ្វើឡើងដោយស្ម័គ្រចិត្ត ទៀងត្រង់ និងគួរទុកចិត្តបានដែរឬទេ ទៅតាមការសមស្រប" ។ *រដ្ឋអាជ្ញា ទល់នឹង Tadic,* សំណុំរឿងលេខ: IT-94-I-T, សេចក្តីសម្រេចលើញត្តិស្នើសុំរបស់មេធាវីការពារក្តីស្តីពីពាក្យចចាមអារ៉ាម, ចុះថ្ងៃទី៥ សីហា ១៩៩៦, (អង្គជំនុំជម្រះសាលា ដំបូង), កថាខណ្ឌទី ១៦ ។

[21] វិធាន ៨៧.៤ នៃវិធានផ្ទៃក្នុង ។

ដើម្បីលាតត្រដាងការពិត - ឯកសារ និងកំណត់ហេតុជាលាយលក្ខណ៍អក្សរដាក់បន្ទុកភាគច្រើន ត្រូវបានមន្ត្រីនានារបស់កម្ពុជាប្រជាធិបតេយ្យបំផ្លាញចោល ហើយការដាក់ជំទាស់ចំពោះឯកសារស្ទួរចម្លើយទាំងនេះ គឺមិនអាចធ្វើទៅបានឡើយ[22] ។

១៨. ជាមួយនឹងសារសំខាន់ដ៏ធំធេងរបស់វា ភស្តុតាងនៅមន្ទីរស-២១ មានបុរេវិនិច្ឆ័យតិចតួចបំផុតសម្រាប់ជនត្រូវចោទ: ដោយគ្មានក្រុមគណៈវិនិច្ឆ័យដែលនឹងដឹកនាំឱ្យដើរខុសផ្លូវនោះ គឺវាមិនអាចមានគ្រោះថ្នាក់ឡើយក្នុងការទទួលយកកំណត់ហេតុ ដែលវាហាក់ដូចជាមានតម្លៃជាភស្តុតាងត្រឹមតែតិចតួចស្តួចស្តើងក៏ដោយ ពីព្រោះថាបន្ទាប់មកគេនឹងធ្វើការវាយតម្លៃជាបន្តបន្ទាប់ឱ្យបានត្រឹមត្រូវទៅតាមស្ថានទម្ងន់របស់វា ។ នៅក្នុងសាលដីការបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍ក្នុងករណី *Fofana* តុលាការ SCSL ដែលមានវិធានស្តីពីភស្តុតាងស្រដៀងគ្នានឹងវិធានរបស់ អ.វ.ត.ក ដែរ[23] បានពន្យល់ថា: “ភស្តុតាងអាចនឹងទទួលយកបាន លុះត្រាតែភស្តុតាងនោះបានបង្ហាញឱ្យឃើញថាមានការពាក់ព័ន្ធ: បញ្ហាស្តីពីភាពអាចជឿទុកចិត្តបាន នៃភស្តុតាងនឹងត្រូវបានគេកំណត់នាពេលក្រោយបន្ទាប់ពីនោះ ហើយក៏មិនមែនជាលក្ខខណ្ឌសម្រាប់ការទទួលយកភស្តុតាងទេ[24] ។

១៩. មេធាវីការពារក្តីអះអាងថា ការទទួលយកភស្តុតាងទាំងនេះ គឺជាការរំលោភទៅលើសិទ្ធិរបស់ជនត្រូវចោទក្នុងការទទួលបាននូវការជំនុំជម្រះដោយយុត្តិធម៌ និងការសន្មត់ជាមុនថាគ្មានទោស[25] ។ ទោះជាយ៉ាងនេះក្តី ដូច Tobial Thienel ធ្វើការកត់សំគាល់ថា គោលការណ៍នៃការជំនុំជម្រះដោយយុត្តិធម៌ ជាប់ទាក់ទងទៅនឹងសិទ្ធិប្រឆាំងនឹងការធ្វើសក្ខីកម្មដាក់បន្ទុកមក

---

[22] Scharf, ត្រង់ទំព័រទី ១៣៧-៣៩ ។

[23] *សូមមើល* វិធាន ៨៩.គ នៃវិធានស្តីពីនីតិវិធី និងភស្តុតាងរបស់តុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូន, ថ្ងៃទី២៧ ខែឧសភា ២០០៨ ។

[24] *ព្រះរាជអាជ្ញា ទល់នឹង Sam Hinga Norman និងគូកន*, សំណុំរឿងលេខ: SCSL-04-14-AR65, Fofana - បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចបដិសេធការដាក់ប្រាក់ធានាឱ្យនៅក្រៅឃុំ, ១១ មីនា ២០០៥ (អង្គជំនុំជម្រះសាលាឧទ្ធរណ៍), ត្រង់កថាខណ្ឌទី២៤ ។ អាចរកបានតាមគេហទំព័រ http://www.sc-sl.org/LinkClick.aspx?fileticket=gcYjozQ1q9U%3d&tabid=193 ។

[25] សំណើរបស់មេធាវីការពារក្តី, ត្រង់កថាខណ្ឌទី ៨ ។

លើខ្លួនឯង[26] ។ នៅទីនេះ គ្មានការភ័យខ្លាចចំពោះការធ្វើសក្ខីកម្មដាក់បន្ទុកមកលើខ្លួនឯងទេ ពីព្រោះ សក្ខីកម្មមិនត្រូវបានធ្វើឡើងដោយជនត្រូវចោទក្នុងពេលដែលកំពុងទទួលទារុណកម្មនោះទេ ប៉ុន្តែផ្ទុយមកវិញ សក្ខីកម្មត្រូវបានធ្វើឡើងដោយអ្នកទោសទាំងឡាយ ដែលត្រូវបានធ្វើទារុណកម្មដោយមន្ត្រីនានានៃកម្ពុជាប្រជាធិបតេយ្យដែលជាអ្នកក្រោមបង្គាប់ ឬធ្វើសកម្មភាពដោយព្រមព្រៀងគ្នាជាមួយជនត្រូវចោទ ឬសហជនជាប់ចោទរបស់ជនត្រូវចោទ ។

**ខ. គោលការណ៍លើកលែងនៅក្នុងមាត្រា១៥ នៃវិធានស្តីពីការបដិសេធភស្តុតាង សម្រាប់ ប្រើប្រាស់ប្រឆាំងនឹងអ្នកប្រព្រឹត្តអំពើទារុណកម្ម គួរត្រូវបានបកស្រាយឲ្យបានទូលំទូលាយ ដើម្បីគាំទ្រដល់គោលបំណងនៃអនុសញ្ញា CAT**

២០. គឺជាការច្បាស់ណាស់ថា ការមិនរាប់បញ្ចូលនូវភស្តុតាងដែលត្រូវបានជំទាស់ នឹងធ្វើឱ្យគោលបំណងនៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម ទទួលបរាជ័យក្នុងការទប់ស្កាត់កុំឱ្យមានការធ្វើទារុណកម្មយ៉ាងប្រាកដ ។ មាត្រា ១៥ មានអត្ថិភាព សម្រាប់បំរើឱ្យអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម និងគោលបំណងក្នុងការទប់ស្កាត់ការធ្វើទារុណកម្មរបស់អនុសញ្ញានេះ ។ អាស្រ័យហេតុនេះ មាត្រា ១៥ មិនអាចប្រើប្រាស់ដើម្បីលុបបំបាត់ន័យរបស់អនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្មបានឡើយ ។ ដូចអតីតអ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិអំពីការធ្វើទារុណកម្មឈ្មោះ P. Koojimans បានពន្យល់ដែរថា សនិទានភាពនៃការដាក់បញ្ចូលមាត្រា ១៥ គឺការទទួលយករបស់តុលាការនូវចម្លើយនានាដែលបានមកដោយសារការធ្វើទារុណកម្ម គឺ "បានទទួលខុសត្រូវចំពោះការកើនឡើងនៃការធ្វើទារុណកម្ម" និងថា ការបដិសេធមិនទទួលភស្តុតាងបែបនេះ មុខជា "លែងផ្តល់ការលើកទឹកចិត្តដល់ការធ្វើទារុណកម្មហេតុដូចនេះ មុខជានឹងលែងធ្វើឱ្យចាប់អារម្មណ៍ចំពោះការធ្វើទារុណកម្មហើយ"[27]។ នៅទីនេះ បើសិនជាសនិទានភាពជាដើមដែលចែងក្នុងវិធានស្តីពីការបដិសេធភស្តុតាងនៃមាត្រា១៥ មិនត្រូវបានយកមកអនុវត្តទេនោះ ករណីលើកលែងចំពោះវិធានដែលអនុញ្ញាតឱ្យប្រើប្រាស់

[26] Thienel, ត្រង់ទំព័រទី ៣៥៦ ។

[27] Scharf, ត្រង់ ១៣៥ ។

ភស្តុតាងប្រឆាំងនឹងពួកអ្នកធ្វើទារុណកម្មនេះ ត្រូវតែទទួលបានការបកស្រាយឱ្យបានទូលំទូលាយ ដើម្បីប្រតិបត្តិតាមគោលបំណងរបស់អនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម[28]។

២១. មេធាវីការពារក្តីបានស្នើថា "ក្នុងការទទួលស្គាល់ឥរិយាបថខាងអសីលធម៌ដ៏គួរស្អប់ខ្ពើមរបស់អ្នកប្រព្រឹត្តអំពើទារុណកម្ម" ភស្តុតាងនេះត្រូវតែបានបដិសេធចោល[29] ។ បើអនុញ្ញាតឱ្យមានសំណើនេះ មុខជាធ្វើឱ្យអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្មនេះរក់រីក្នុងអារម្មណ៍មិនខាន ។ ការពិត សហព្រះរាជអាជ្ញាបានដាក់សេចក្តីសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរដោយចោទប្រកាន់ដោយផ្នែកខ្លះថា ជនត្រូវចោទបានចូលរួមនៅក្នុងការធ្វើទារុណកម្ម ដែលនេះជាការគោរព និងលើកស្ទួយយ៉ាងច្បាស់ចំពោះច្បាប់ដែលហាមឃាត់ការធ្វើទារុណកម្ម ។ នៅក្នុងកាលៈទេសៈទាំងនេះ វាគ្មានន័យអ្វីឡើយ ដើម្បីអនុវត្តគោលនយោបាយមួយ នៅក្នុងស្ថានភាពដែលគ្មានការបារម្ភណាមួយជួយគាំទ្រដល់គោលនយោបាយនេះ៖ មានន័យថាគេមិនមានការបារម្ភណាមួយដែលថា ការទទួលយកភស្តុតាងដែលមានអំណាចជាប្រវត្តិសាស្ត្រនេះ អាចជាការលើកស្ទួយដល់ការធ្វើទារុណកម្ម ឬក៏ជាការលើកទឹកចិត្តដល់អ្នកប្រព្រឹត្តអំពើទារុណកម្មនោះឡើយ ។

២២. ពុំមានអ្នកប្រព្រឹត្តអំពើទារុណកម្មណាម្នាក់អាចរួចខ្លួនដោយវិធីណាមួយនោះឡើយ ប្រសិនបើភស្តុតាងនេះត្រូវបានទទួលយក - មិនមែនអ្នកសួរចម្លើយ ហើយក៏មិនមែនមេដឹកនាំរបស់ពួកគេដែលស្ថិតក្នុងកាត់ទោសដែរ ។ តាមពិត អ្វីដែលផ្ទុយពីនេះទើបជាការពិត ។ ការរារាំងចំពោះភស្តុតាងដែលបានតវ៉ា មុខជានឹងលើកទឹកចិត្តដល់អ្នកទាំងឡាយណា ដែលបានចូលរួមធ្វើឱ្យមានការធ្វើទារុណកម្ម ដោយអនុញ្ញាតឱ្យពួកគេប្រើប្រាស់នូវច្បាប់អន្តរជាតិនានាដែលត្រូវបានបង្កើតឡើងដើម្បីទប់ស្កាត់ និងផ្តន្ទាទោសចំពោះការធ្វើទារុណកម្ម ដើម្បីគេចផុតពីការទទួលខុសត្រូវ ។ លើសពីនេះទៀត គេពុំមានការព្រួយបារម្ភអំពី "ចំណោទដ៏រអិល" នោះទេ៖ ប្រសិនបើមេដឹកនាំនៃរបបផ្សេងមួយទៀត ដែលធ្វើទារុណកម្មលើប្រជាជនរបស់ខ្លួនផ្ទាល់ ត្រូវបានគេនាំយកមកកាត់ទោសនាពេលអនាគត វិធានដែលថា ជនទាំងឡាយដែលបានធ្វើទារុណ

---

[28] *សូមមើល* គោលការណ៍ណែនាំរបស់ អសប, លេខ ១៦ ។

[29] សំណើរបស់មេធាវីការពារក្តី, កថាខណ្ឌទី ១ ។

កម្មមិនអាចគេចផុតពីច្បាប់ប្រឆាំងនឹងការធ្វើទារុណកម្មនោះ និងជួយដល់ការកាត់ទោសមេដឹកនាំបែបនោះ ។

## គ. ផ្នែកខ្លះនៃភស្តុតាងដែលបានតម្កល់នៅក្នុងចម្លើយសារភាព គឺអាចទទួលយកបាន

២៣. សំណើរបស់មេធាវីការពារក្តីខ្វះភាពជាក់លាក់ ចំពោះប្រភេទភស្តុតាងជាក់លាក់ដែលបានទទួលតាមរយៈការធ្វើទារុណកម្ម និងថាអាស្រ័យហេតុនេះ ត្រូវតែបានច្រានចោល បើធៀបនឹងភស្តុតាងមិនបានទទួលតាមរយៈការធ្វើទារុណកម្ម ដែលគ្មានការជំទាស់។ ដើម្បីបញ្ជាក់បំភ្លឺ សហព្រះរាជអាជ្ញាជឿថា ភស្តុតាងដែលលើកឡើងនេះ គឺជាសក្ខីកម្មដែលបានធ្វើឡើងដោយអ្នកទោសដែលគេបានសួរចម្លើយរួច នៅក្នុងចម្លើយសារភាពជាលាយលក្ខណ៍អក្សរ។ ភស្តុតាងប្រភេទដទៃទៀត ដែលគួរឱ្យកត់សំគាល់គឺ ចំណារនៅលើចម្លើយសារភាព និងព័ត៌មានជីវប្រវត្តិ ដែលទទួលបាននៅពេលចុះឈ្មោះ មិនមែនជាបញ្ហាទេ ។ អាស្រ័យដូចនេះ សហព្រះរាជអាជ្ញា ចង់ពិភាក្សាលើបញ្ហានិមួយៗតាមលំដាប់ ។

### i. សក្ខីកម្មជាក់លាក់មួយចំនួននៅក្នុងចម្លើយសារភាពមានសញ្ញាបង្ហាញពីភាពជឿទុកចិត្តបានអនុគ្រោះដល់ការទទួលយក

២៤. តាមមូលដ្ឋាននៃករណីនិមួយៗ មានប្រភេទសក្ខីកម្មខុសៗគ្នាដែលមាននៅក្នុងចម្លើយសារភាពនៅមន្ទីរស-២១ ដោយមានផ្អែកពីកំរិតនៃភាពជឿទុកចិត្តបាន អនុគ្រោះដល់ការទទួលយក[30]។ សក្ខីកម្ម អំពីឋានានុក្រម ការប្រាស្រ័យទាក់ទង និងគោលនយោបាយរបស់កម្ពុជាប្រជាធិបតេយ្យ[31] ត្រូវបានបង្កើតឡើងដោយជនរងគ្រោះពីម្នាក់ទៅជនគ្រោះម្នាក់ទៀត ដែលអនុញ្ញាត

---

[30] *សូមមើល* Stephen Heder និង Brian D. Tittemore, "បេក្ខជនប្រាំពីរនាក់សម្រាប់ការចោទប្រកាន់, គណនេយ្យភាពចំពោះបទឧក្រិដ្ឋរបស់ខ្មែរក្រហម" ["Seven Candidates for Prosecution, Accountability for the Crimes of Khmer Rouge"], ការិយាល័យស្រាវជ្រាវឧក្រិដ្ឋកម្មសង្គ្រាម, សាកលវិទ្យាល័យ អាមេរិក: (2001), អាចមាននៅ http://www.wcl.american.edu/warcrimes/khmerrouge.pdf?rd=1, ទំព័រទី ២៦-២៨ ។ [*ចាប់ពីនេះតទៅហៅថា* "Heder"] ។

[31] ឧទាហរណ៍ដ៏ល្អមួយ គឺសក្ខីកម្មចេញពីចម្លើយសារភាពដែលអាចកំណត់បានពីគោលនយោបាយនៃ "វដ្តនៃការសម្រិតសម្រាំង" ដែលបានអនុវត្តនៅមន្ទីរស-២១ និងជនត្រូវចោទបានធ្វើអំពើនៅលើសក្ខីកម្មទាំងនោះ ។ ជាឧទាហរណ៍ ប្រសិនបើនៅក្នុងចម្លើយសារភាព

ឱ្យមានការបញ្ជាក់ការពិតស៊ីសង្វាក់គ្នា ពីប្រភពមួយទៅប្រភពមួយទៀត ព្រមទាំងបណ្តុំនៃភស្តុតាងដែលមិនមែនជាភស្តុតាងទារុណកម្មដទៃទៀត នៅក្នុងសំណុំរឿង ។ ពុំមានបុគ្គលណាម្នាក់ដែលផ្តុកនូវការយល់ដឹងតែម្នាក់ឯងអំពីការងារខាងក្នុងនៃរបបកម្ពុជាប្រជាធិបតេយ្យនោះទេ ។ លើសពីនេះទៀត ការសួរចម្លើយទាំងនេះត្រូវបានគេធ្វើឡើងដើម្បីបញ្ជាក់ពីពួកក្បត់ ឬចារកម្មដែលគេបានចោទប្រកាន់ អំពីការទទួលខុសត្រូវចំពោះ "ការបរាជ័យនៃគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា"[32] ដូច្នេះហើយ បុគ្គលិកមន្ទីរស-២១ មានការលើកទឹកចិត្តគ្រប់យ៉ាងដើម្បីធ្វើឱ្យប្រាកដថា គោលនយោបាយបក្សកុម្មុយនីស្តកម្ពុជាត្រូវបានគេថ្លែងយ៉ាងត្រឹមត្រូវ ។ ប្រការដែលគួរឱ្យកត់សម្គាល់បំផុតនោះគឺ ពុំមានជនរងគ្រោះពីមន្ទីរស-២១ ណាម្នាក់ ដែលត្រូវបានគេធ្វើទារុណកម្ម ដើម្បី ជាឧទាហរណ៍ "ឱ្យឆ្លើយសារភាព" អំពីគោលនយោបាយនានារបស់កម្ពុជាប្រជាធិបតេយ្យនោះទេៈ ប្រភេទព័ត៌មាននេះ គឺជាបរិបទប្រឆាំងនឹង ចម្លើយសារភាពក្លែងក្លាយដែលបានធ្វើឡើងដោយបង្ខំ មានន័យថាៈ បង្ខំឱ្យ*រំលោភ*ទៅលើគោលនយោបាយរបបកម្ពុជាប្រជាធិបតេយ្យ[33] ។ ការព្រួយបារម្ភថា ជនរងគ្រោះដែលរងការធ្វើទារុណកម្មនឹងនិយាយអ្វីមួយ ដើម្បីឱ្យបញ្ឈប់ការធ្វើទារុណកម្មទៅលើរូបគាត់ មិន កាត់បន្ថយនូវចម្លើយ ដែលបានឆ្លើយដោយជនរងគ្រោះនោះទេ នៅពេលដែលចម្លើយទាំងនោះ មិនចំចំណុចនៃការសួរចម្លើយ ឬជនរងគ្រោះមិនទទួលបានការលើកទឹកចិត្តឱ្យឆ្លើយភូតកុហក ពីព្រោះអ្នកសួរចម្លើយខ្លួនឯងផ្ទាល់ ជាឧទាហរណ៍ បានដឹងអំពីល័ក្ខខ័ណ្ឌត្រូវនៃគោលនយោ បាយរបស់កម្ពុជាប្រជាធិបតេយ្យរួចទៅហើយ[34] ។ ទោះជាយ៉ាងណាក្តី សក្ខីកម្ម

---

មួយ ជនរងគ្រោះនៃអំពើទារុណកម្មឈ្មោះ "ក" បានចង្អុលប្រាប់ថា "ខ" ជាជនក្បត់ ដែលបន្ទាប់មកត្រូវបានគេនាំជននេះមកមន្ទីរស-២១ ហើយបន្ទាប់មកទៀត "ខ" បានចង្អុលប្រាប់ស្រដៀងគ្នានេះថា "គ" ជាជនក្បត់ ដែលត្រូវបានគេនាំមកមន្ទីរស-២១ ជាបន្តបន្ទាប់ ។ល។ បន្ទាប់មកទៀត ចម្លើយសារភាពទាំងអស់នេះ គួរតែត្រូវបានទទួលយកជាភស្តុតាងសម្រាប់បង្ហាញអំពីគោលនយោបាយសម្រិត សម្រាំង របស់កម្ពុជាប្រជាធិបតេយ្យដែលត្រូវបានគេអនុវត្តនៅមន្ទីរស-២១ ។

[32] Heder, នៅទំព័រទី ២៩ ។

[33] Heder, នៅទំព័រទី ២៩ ("ទោះជាយ៉ាងណា គួរកត់សម្គាល់ថា ចម្លើយសារភាពត្រូវបានទទួលយ៉ាងជាប់លាប់ដោយមិនមានការជំទាស់ទៅនឹងអត្ថិភាពនៃគោលនយោបាយទាំងនោះ។ ការពិតទាំងនេះបានបង្កើតនូវចនាសម្ព័ន្ធដ៏សំខាន់ដែល "ការទទួលយក" ដោយបង្ខំ... ត្រូវបានធានា") ។

[34] ការណ៍នេះអនុវត្តដោយស្មើគ្នាចំពោះឋានានុក្រម និងការប្រាស្រ័យទាក់ទងគ្នាក្នុងនាមជាអ្នកសួរចម្លើយ ឬជាបុគ្គលិកមន្ទីរស-២១ដែលបានដឹងជាសម្ងាត់ មុននឹងមានការសួរចម្លើយណាមួយ អំពីអ្វីដែលជាឋានានុក្រមរបស់បក្សកុម្មុយនីស្តកម្ពុជា និងពីរបៀបរបបដែលការប្រាស្រ័យទាក់ទងរបស់កម្ពុជាប្រជាធិបតេយ្យត្រូវបានធ្វើឡើង ។

ប្រឆាំងនឹងខ្លួនឯង ឬប្រឆាំងអ្នកដទៃដែលបានរកឃើញនៅក្នុងចម្លើយសារភាព គឺជាសក្ខីកម្ម ដែលអាច ឱ្យគេពិចារណាបានថា មិនអាចជឿទុកចិត្តបាន ឬត្រូវបានច្រានចោលតាមមាត្រា ១៥ នៃ អនុសញ្ញា CAT ។

២៥. ព័ត៌មានអំពីប្រវត្តិរូបដែលមាននៅក្នុងចម្លើយសារភាពនានា រួមមាន *នៅក្នុងចំណោមព័ត៌មានផ្សេងៗទៀត* ឈ្មោះរបស់ថ្នាក់លើ និងអ្នកនៅក្រោមបង្គាប់ និងទីកន្លែងពីមុនរបស់អ្នកជាប់ឃុំ ដែលអាចជឿទុកចិត្តបាន និង អាចទទួលយកបាន ។ អ្នកជាប់ឃុំឃាំងជាច្រើននាក់ត្រូវបានគេសួរចម្លើយច្រើនលើកច្រើនសារ ហើយចម្លើយសារភាពពីដំបូងបានផ្តោតទៅលើព័ត៌មានជីវប្រវត្តិ[35] ។ អតីតបុគ្គលិកមន្ទីរស-២១ ដែលបានសម្ភាសន៍ដោយ ស.ច.ស បានបំភ្លឺថា នៅក្នុងករណីទាំងនេះ ការធ្វើទារុណកម្មមិនបានធ្វើឡើយរហូតដល់ការសួរចម្លើយពេលក្រោយ[36]។ដូច្នេះព័ត៌មានជីវប្រវត្តិដែលបានរកឃើញនៅក្នុងការសួរចម្លើយពីដំបូងនោះអាចឱ្យគេអះអាងបានថា មិនមែនបានមកពីការធ្វើទារុណកម្មទេ ហើយអាចជឿទុកចិត្តបាន ថាជាផលវិបាកមួយ ។

២៦. មេធាវីការពារក្តីទទួលស្គាល់ថា "ការពិត ប្រសិនបើគេអាចកំណត់បានថា ភស្តុតាងបែបនេះមិនមែនទទួលបានដោយការធ្វើទារុណកម្ម វាមិនធ្លាក់ចូលក្នុងមាត្រា ១៥ នៃអនុសញ្ញា CAT ទេ"[37] ។ មេធាវីការពារក្តីទទួលស្គាល់បន្ថែមទៀតថា "ទាក់ទងនឹងបញ្ហាបឋមដែលមិនទទួលបានដោយការធ្វើទារុណកម្ម... មេធាវីការពារក្តីបានសន្និដ្ឋានដោយមិនជំទាស់ទេ"[38] ។ សហព្រះរាជអាជ្ញាឯកភាព និងថា ភស្តុតាងនៅក្នុងសំណុំរឿងពិតជាមានបញ្ចូលព័ត៌មានជីវប្រវត្តិដែលបានយកពីអ្នកទោស មុននឹងពួកគេត្រូវបានគេធ្វើទារុណកម្ម ។

---

[35] [redacted]

[36] [redacted]

[37] សំណើរបស់មេធាវីការពារក្តី, ត្រង់កថាខ័ណ្ឌទី ៣៩ ។

[38] សំណើរបស់មេធាវីការពារក្តី, ត្រង់កថាខ័ណ្ឌទី ៤២ ។

២៧. Tobias Thienel បានធ្វើការកត់សម្គាល់ថា មាត្រា ១៥ មិនបានចែងអំពីថាតើភាគីណាមួយជាអ្នកទទួលបន្ទុកលើភស្តុតាង នៅក្នុងការបង្ហាញឲ្យឃើញថា តើចម្លើយត្រូវបានធ្វើឡើងដោយសារការធ្វើទារុណកម្មដែរឬទេ[39] ។ អ្នករាយការណ៍ពិសេសអំពីរបាយការណ៍ស្តីពីការធ្វើទារុណកម្មដែលធ្វើឡើងនៅក្នុងរឿងក្តីរបស់ *A និង ជនដទៃៗទៀត ទល់នឹង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង* *Mounir el Montassadeq* គឺរាំងតែចំពោះភស្តុតាងណាដែល *បានបង្ហាញថា* បានមកដោយសារការធ្វើទារុណកម្មប៉ុណ្ណោះ និង "ហាក់ដូចជាមិនផ្លាស់ប្តូរបន្ទុកនៃភស្តុតាងទៅខាងអាជ្ញាធររដ្ឋាភិបាលទេ"[40] ។ ការព្រួយបារម្ភរបស់អ្នករាយការណ៍ពិសេសពាក់ព័ន្ធនឹងវិធីសាស្ត្រនេះ គឺបានផ្អែកទៅលើមូលដ្ឋានទស្សនៈទាននៃភាពយុត្តិធម៌ចំពោះជនរងគ្រោះដែលត្រូវបានគេធ្វើទារុណកម្ម ។ នៅពេលដែលជនជាប់ចោទត្រូវបានចោទប្រកាន់ពីបទធ្វើទារុណកម្ម គឺជាជនដែលខំស្វែងរកដើម្បីបដិសេធភស្តុតាង ការព្រួយបារម្ភពីភាពយុត្តិធម៌នេះលេចឡើងនៅក្នុងគំនិតរបស់អ្នករាយការណ៍ពិសេស ។ នៅក្នុងករណីនេះ គឺជនដែលត្រូវចោទប្រកាន់ពីបទធ្វើទារុណកម្មដែលជាអ្នកដែលមានសមត្ថភាពជាងគេបំផុត ក្នុងការបង្ហាញភស្តុតាងថាតើមានការធ្វើទារុណកម្ម ឬគ្មាន ពីព្រោះជនរងគ្រោះនៃអំពើទារុណកម្មសឹងតែទាំងអស់ ត្រូវបានគេសម្លាប់ចោល។ ហេតុនេះ មាត្រា១៥ មិនអាចរាំងមិនឲ្យទទួលយកនូវភស្តុតាងនេះបានទេ ។

២៨. អនុសញ្ញាទីក្រុងវីយែនស្តីពីច្បាប់សន្ធិសញ្ញាបានលើកឡើងថា អនុសញ្ញាស្តីពីការប្រឆាំងនឹងការធ្វើទារុណកម្ម ត្រូវតែបានគេបកស្រាយ " ដោយគិតផ្អែកទៅតាមកម្មវត្ថុនិងគោលបំណងរបស់អនុសញ្ញានេះ"[41] ។ យោងតាមការបកស្រាយនេះ ករណីលើកលែងនៅក្នុងមាត្រា ១៥ ត្រូវតែអនុវត្តឲ្យបានទូលំទូលាយនៅក្នុងករណីនេះ - មិនគ្រាន់តែដើម្បីអនុញ្ញាតឲ្យទទួលយកនូវចម្លើយនានាដើម្បីធ្វើជាភស្តុតាងដែលបង្ហាញថា ការធ្វើទារុណកម្មបានកើតឡើងប៉ុណ្ណោះទេ ប៉ុន្តែដើម្បីឲ្យទទួលយកនូវភស្តុតាងទាំងអស់ ប្រឆាំងនឹងអ្នកធ្វើទារុណកម្មទាំងឡាយដែលមាន

---

[39] Thienel, ត្រង់ទំព័រទី ៣៥៤ ។

[40] របាយការណ៍ស្តីពីការធ្វើទារុណកម្មរបស់អ្នករាយការណ៍ពិសេស, ត្រង់កថាខណ្ឌទី ៦៥ ។

[41] អនុសញ្ញាទីក្រុងវីយែនស្តីពីច្បាប់សន្ធិសញ្ញា, 155 U.N.T.S. 331, ចុះថ្ងៃទី២៣ ឧសភា ១៩៦៩, មាត្រា ៣១ ។

សញ្ញាបង្ហាញថាមានភាពដែលគួរជឿទុកចិត្តបាន និងដែលអាចផ្តល់នូវស្ថានទម្ងន់ណាមួយដោយគណៈវិនិច្ឆ័យលើអង្គហេតុ ។

ii. <u>ចម្លើយមួយចំនួន គឺអាចទទួលយកបានប្រឆាំងនឹងជនត្រូវចោទ ដោយមិនគិតអំពីវត្ថុមានជាក់ស្តែងរបស់ពួកគេ នៅពេលធ្វើទារុណកម្មទេ</u>

២៩. មាត្រា ១៥ បានទទួលស្គាល់យ៉ាងច្បាស់លាស់ថា ភស្តុតាងដែលទទួលបានមកដោយសារការធ្វើទារុណកម្មគឺអាចទទួលយកបាន នៅពេលដែលភស្តុតាងនោះត្រូវបានផ្តល់ឱ្យ "ប្រឆាំងនឹងជនជាប់ចោទពីបទធ្វើទារុណកម្ម ដើម្បីធ្វើជាភស្តុតាងតាមចម្លើយទាំងឡាយដែលបានឆ្លើយប្រាប់" ។ ករណីលើកលែងនេះ បានអនុញ្ញាតយ៉ាងច្បាស់លាស់ឱ្យទទួលយកនូវរាល់ភស្តុតាងទាំងអស់ដែលបានធ្វើឡើងដោយសារការធ្វើទារុណកម្ម ក្នុងគោលបំណងដើម្បីបង្ហាញថាចម្លើយទាំងនោះត្រូវបានធ្វើឡើងដោយសារការធ្វើទារុណកម្ម ។ គោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិ បានធ្វើឱ្យករណីលើកលែងកាន់តែមានលក្ខណៈទូលំទូលាយ និងអនុញ្ញាតឱ្យមានការប្រើប្រាស់ភស្តុតាងប្រឆាំងនឹងអ្នកធ្វើទារុណកម្មទាំងឡាយ ដោយមិនគិតពីគោលបំណងនៃការប្រើប្រាស់ភស្តុតាងនោះឡើយ ។

៣០. ករណីលើកលែងទាំងនេះ អនុវត្តចំពោះជនត្រូវចោទដោយសារហេតុផលជាច្រើន ។ ទីមួយ ពាក្យពេចន៍ នៅក្នុងករណីលើកលែងនៅក្នុងវិធានស្តីពីការបដិសេធភស្តុតាង ដែលចែងក្នុងមាត្រា ១៥ គ្របដណ្តប់លើ "ជនណាក៏ដោយដែលត្រូវបានចោទប្រកាន់ពីបទធ្វើទារុណកម្ម" បានពិពណ៌នាឱ្យបានងាយយល់ពីជនណាក៏ដោយ ដែលត្រូវបានចោទប្រកាន់ពីបទធ្វើទារុណកម្ម។ ស្រដៀងគ្នានេះដែរ គោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិអនុញ្ញាតឱ្យគេទទួលយកភស្តុតាងប្រភេទនេះសម្រាប់ប្រឆាំងនឹង "ជនទាំងឡាយណាដែលបានប្រើប្រាស់នូវវិធីសាស្ត្របែបនេះ"។ លើសពីនេះទៅទៀត និយមន័យដ៏ជាក់លាក់របស់ពាក្យការធ្វើទារុណកម្មដែលចែងនៅក្នុងអនុសញ្ញាស្តីពីការប្រឆាំងនឹងការធ្វើទារុណកម្ម ត្រង់មាត្រា ១ បានរួម

បញ្ចូលទាំងការចូលរួមរបស់មន្ត្រីនានារបស់រដ្ឋាភិបាល ដែលបានធ្វើការកំរិតកំណត់អំពីការទទួលខុសត្រូវរបស់អ្នកស្នេចម្លើយម្នាក់ៗ ឬអ្នកប្រព្រឹត្តដែលមិនសមហេតុសមផល[42]។

៣១. ទីពីរ ជនត្រូវចោទទាំងឡាយដែលត្រូវបានគេចោទប្រកាន់ថា គឺជាផ្នែកនៅក្នុងការរួមគំនិតប្រព្រឹត្តបទឧក្រិដ្ឋណាមួយ ឬនៅក្នុងសហកម្មឧក្រិដ្ឋកម្មរួមជាមួយអ្នកស្នេចម្លើយទាំងឡាយដែលបានធ្វើការក្រោមបង្គាប់របស់ពួកគាត់ ។ ភាសានៅក្នុងអនុសញ្ញាស្តីពីការប្រឆាំងនឹងការធ្វើទារុណកម្មខ្លួនឯងផ្ទាល់ក៏បានបង្ហាញដែរថា ការសមគំនិតប្រភេទនេះ គឺមានបំណងចង់ឱ្យដាក់បញ្ចូលទៅក្នុងនិយមន័យនៃពាក្យថា អ្នកធ្វើទារុណកម្ម។ អនុសញ្ញាស្តីពីការប្រឆាំងនឹងការធ្វើទារុណកម្ម ត្រង់មាត្រា ៤ បានចែងថា "រដ្ឋជាភាគីនីមួយៗ ត្រូវតែធានាថា រាល់ការធ្វើទារុណកម្មទាំងអស់ អនុលោមតាមច្បាប់ព្រហ្មទណ្ឌរបស់ខ្លួនគឺសុទ្ធតែជាបទល្មើស ។ ត្រូវអនុវត្តដូចគ្នានេះដែរ ចំពោះការប៉ុនប៉ងប្រព្រឹត្តការធ្វើទារុណកម្ម និងចំពោះអំពើដែលប្រព្រឹត្តដោយជនណាម្នាក់ដែលបង្កើតជាបទសមគំនិត ឬការចូលរួមនៅក្នុងការធ្វើទារុណកម្ម"[43] ។

៣២. ទីបី ទ្រឹស្តីដែលត្រូវបានបង្កើតបានយ៉ាងល្អស្តីពីការទទួលខុសត្រូវ ក្នុងការបញ្ជាបានកំណត់ថា បុគ្គលទាំងឡាយអាចត្រូវទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មអន្តរជាតិនានា ទោះបីជានៅពេលដែលបុគ្គលទាំងនោះមិនមានវត្តមាននៅក្នុងពេលប្រព្រឹត្តឧក្រិដ្ឋកម្មនោះក៏ដោយ[44]។ ការទទួលខុសត្រូវក្នុងការបញ្ជាតម្រូវឱ្យមានធាតុផ្សំបីយ៉ាង៖ ទី១) ទំនាក់ទំនងរវាងចៅហ្វាយនាយ-កូនចៅ ក្រោមបង្គាប់ ។ ទី២) ការដឹងរបស់ចៅហ្វាយនាយ ឬចេតនាឧក្រិដ្ឋ ។ ទី៣) ចៅហ្វាយនាយបានខកខានមិនបានទប់ស្កាត់ ឬមិនបានដាក់ទណ្ឌកម្មចំពោះអំពើដែលបានប្រព្រឹត្តដោយកូនចៅក្រោមបង្គាប់របស់ខ្លួន[45] ។ តាមច្បាប់ អ.វ.ត.ក មាត្រា ២៩ ចែងថា ជនសង្ស័យត្រូវទទួលខុសត្រូវចំពោះការប្រព្រឹត្តិរបស់កូនចៅរបស់ខ្លួន នៅពេលដែលពួកគេ "បានដឹង ឬមានហេតុផលដែលធ្វើឱ្យដឹងថាកូនចៅក្រោមបង្គាប់បម្រុងនឹង" ប្រព្រឹត្តបទល្មើស

[42] អនុសញ្ញា CAT, មាត្រា ១.១ ។

[43] អនុសញ្ញា CAT, មាត្រា ៤.១ ។

[44] *សូមមើល* លក្ខន្តិកៈទីក្រុងរ៉ូមនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ, UN Doc. A/CONF, 183/9, ១៧ កក្កដា ១៩៩៨, មាត្រា ២៨ ។

[45] មាត្រា ២៩ នៃច្បាប់ អ.វ.ត.ក ។ មាត្រា ៧.៣ នៃច្បាប់លក្ខន្តិកៈសម្រាប់តុលាការ ICTY, កញ្ញា ២០០៨ ។

ណាមួយ ហើយដែលខ្លួនមិនបានទប់ស្កាត់ ឬមួយក៏មិនបានដាក់ទណ្ឌកម្មចំពោះអំពើនោះ ។ ផ្អែកតាមភាពសមហេតុសមផលដូចគ្នានេះ ចៅហ្វាយនាយរបស់ពួកអ្នកសួរចម្លើយ នៅមន្ទីរ ស-២១ "ត្រូវបានចោទប្រកាន់ពីបទធ្វើទារុណកម្ម" អនុលោមតាមមាត្រា ១៥ ។

iii. <u>ចម្លើយមួយចំនួន អាចទទួលយកបាន ដោយសារវាជាភស្តុតាងដែលត្រូវបានអ្នកជំនាញអាចជឿទុកចិត្តបាន ឬម្យ៉ាងទៀតដោយសារមិនបិតនៅក្នុងការបដិសេធចោល</u>

៣៣. ដោយសមហេតុសមផល បើប្រភេទនៃចម្លើយដែលត្រូវបានពិភាក្សាកន្លងមកនេះ អាចទទួលយកបានយ៉ាងដូច្នេះ នោះមតិ យោបល់របស់អ្នកជំនាញដែលពាក់ព័ន្ធមន្ទីស-២១ ក៏អាចទទួលយកបានដូចគ្នាដែរ។ ក្នុងជម្រើសមួយវិញទៀត ទោះជាយ៉ាងដូច្នេះក៏ដោយសូម្បីតែចម្លើយទាំងនោះត្រូវបាន ចាត់ទុកថាមិនអាចទទួលយកបានដោយសារតែចម្លើយខ្លួនឯងវិញនោះ ក៏វាមិនបាន ច្រានចោលជាមុននូវមតិយោបល់របស់អ្នកជំនាញនោះទេ ។ មិនមានមូលដ្ឋាននៅក្នុងច្បាប់ ណាមួយសម្រាប់ អ.វ.ត.ក នៅក្នុងការរារាំងសាក្សីជំនាញមិនឱ្យមានមតិយោបល់ដោយសំអាងលើភស្តុតាង ដែលមានពាក់ព័ន្ធនឹងការធ្វើទារុណកម្ម និងមានហេតុផលល្អ នោះទេ ។ សក្ខីកម្មរបស់អ្នកជំនាញ អាចត្រូវបានធ្វើការសាកល្បងតាមរយៈការសាកសួរដេញដោលសាក្សីរបស់ភាគីបដិបក្ខ (cross-examination) ស្របតាមវិធាន ៨៤ នៃវិធានផ្ទៃក្នុង ហើយអង្គភាពតុលាការផ្សេងៗទៀតនៃអ.វ.ត.ក អាចនឹងចាត់ទុកថាតើសក្ខីកម្មរបស់អ្នកជំនាញមានសារៈសំខាន់ត្រឹមត្រូវកម្រិតណាបាន តាមរយៈការសាកល្បងនោះ ។

៣៤. តុលាការនានារបស់អង្គការសហប្រជាជាតិ គាំទ្រដល់ការអនុញ្ញាតឱ្យអ្នកជំនាញនានាប្រើប្រាស់ការវិនិច្ឆ័យរបស់ខ្លួនពួកគេផ្ទាល់ ដើម្បីធ្វើជាប្រភពដែលត្រូវពិគ្រោះយោបល់ជាមួយ ដើម្បីសាកល្បងលើការវិនិច្ឆ័យនិងសក្ខីកម្មរបស់អ្នកជំនាញនោះ តាមរយៈការសួរដេញដោលនោះ រួចហើយទទួលយកនូវសក្ខីកម្មរបស់អ្នកជំនាញនោះ អាស្រ័យទៅលើការវិនិច្ឆ័យរបស់តុលាការទៅតាមស្ថានទម្ងន់ត្រឹមត្រូវដើម្បីយល់ព្រមលើសក្ខីកម្មនោះ ។ នៅក្នុងរឿងក្តី *Prosecutor v. Bagosora* មេធាវីការពារក្តីបានតវ៉ាជំទាស់ទៅនឹងការទទួលយកចម្លើយរបស់សាក្សីជាអ្នកជំនាញ ដោយបានតវ៉ាចំពោះភាពអាចជឿទុកចិត្តបាននៃឯកសារនានាដែលចម្លើយ

នោះបានយកធ្វើជាសម្អាង។ អង្គជំនុំជម្រះសាលាដំបូងនៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ្វ៉ាន់ដា (ICTR) បានសម្រេចថា "ជាការពិត មេធាវីការពារក្តីអាចចោទសំណួរអំពីការផ្តល់មតិយោបល់ដែលមូលដ្ឋាននៃភស្តុតាង នៅក្នុងពេលផ្តល់សក្ខីកម្មរបស់សាក្សី ។ អង្គជំនុំជម្រះនោះចាត់ទុកថា ការចោទសួរដេញដោល គឺជាយន្តការសមស្របសម្រាប់លើកឡើងអំពីការព្រួយបារម្ភផ្សេងៗរបស់មេធាវីការពារក្តី។ អង្គជំនុំជម្រះនេះ បន្ទាប់ពីបានស្តាប់ការបូកសរុបភស្តុតាងរួចមក ពេញចិត្តក្នុងការដោះស្រាយចំពោះបញ្ហានៃភាពដែលអាចជឿទុកចិត្តបានដែលត្រូវបានតវ៉ាជំទាស់ នៅពេលដែលកំពុងពិចារណាលើអង្គសេចក្តីនៃករណីរឿងក្តី"[46] ។ ស្រដៀងគ្នានេះដែរ តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី (ICTY) បានសម្រេចកាលពីពេលថ្មីៗនេះថា "ទោះជាយ៉ាងណាក្តី ការព្រួយបារម្ភទាំងនេះ [អំពីភាពដែលអាចជឿទុកចិត្តបាននៃប្រភពដែលត្រូវបានប្រើប្រាស់ដោយអ្នកជំនាញ] ទាំងនេះមិនប៉ះពាល់ដល់ភាពដែលទទួលយកបាននៃរបាយការណ៍នេះទេ តែវា អាចប៉ះពាល់ដល់ស្ថានទម្ងន់ដែលត្រូវផ្តល់ឲ្យទៅលើភស្តុតាង [របស់អ្នកជំនាញ]"[47] ។ យុត្តា-ធិការដទៃៗទៀត ដូចជាសហរដ្ឋអាមេរិកនិងប្រទេសកាណាដា សុទ្ធតែអនុញ្ញាតឲ្យទទួលយកនូវសក្ខីកម្មរបស់អ្នកជំនាញដែលអាចយកទៅឲ្យភាគីម្ខាងទៀត ធ្វើការចោទសួរដេញដោល និងធ្វើការថ្លឹងថ្លែងដោយគណៈវិនិច្ឆ័យលើអង្គហេតុ[48] ។ ក្នុងការធ្វើដូចនេះ អង្គហេតុ ឬទិន្នន័យណាក៏ដោយអាចយកទៅប្រើប្រាស់ធ្វើជាមូលដ្ឋាននៃសក្ខីកម្មរបស់អ្នកជំនាញបាន។

---

[46] *រដ្ឋអាជ្ញា ទល់នឹង Bagosora*, សំណុំរឿងលេខ: ICTR-98-41-T, សេចក្តីសម្រេចលើសំណើសុំបដិសេធការស្តាប់ចម្លើយរបស់សាក្សីជំនាញ Filip Reyntjens, ចុះថ្ងៃទី២៨ កញ្ញា ២០០៤ (អង្គជំនុំជម្រះសាលាដំបូង), ត្រង់កថាខណ្ឌទី ៩ ។

[47] *សូមមើល រដ្ឋអាជ្ញា ទល់នឹង Peršić,* សំណុំរឿងលេខ: IT-04-81-IT, សេចក្តីសម្រេចលើរបាយការណ៍របស់អ្នកជំនាញ Richard Philips, ចុះថ្ងៃទី១០ មីនា ២០០៩ (អង្គជំនុំជម្រះសាលាដំបូង), ត្រង់កថាខណ្ឌទី ១៨ ។

[48] វិធាន ៧០៣ នៃ ធានស្តីពីភស្តុតាងសម្រាប់សហព័ន្ធ សរអា ចែងថា៖ "អង្គហេតុ ឬ ទិន្នន័យ [ដែលជាមូលដ្ឋាននៃមតិយោបល់] ចាំបាច់ត្រូវតែទទួលយកធ្វើជាភស្តុតាង ក្នុងគោលបំណងដើម្បីឲ្យមតិយោបល់ ឬការពិចារណានោះត្រូវបានទទួលយក ។ បើមិនដូច្នោះទេ អង្គហេតុ ឬទិន្នន័យដែលមិនអាចទទួលយកបានទាំងនោះ មិនត្រូវបានដាក់បង្ហាញជូនដល់ក្រុមប្រឹក្សាវិនិច្ឆ័យឡើយ... លើកលែងតែតុលាការធ្វើការកំណត់ថា តម្លៃជាភវនីយភាពនៃអង្គហេតុ ឬទិន្នន័យទាំងនោះបានជួយដល់ក្រុមប្រឹក្សាវិនិច្ឆ័យដើម្បីធ្វើការវាយតម្លៃលើមតិយោបល់របស់អ្នកជំនាញថា វាមានសារៈសំខាន់ធ្ងន់ជាងអនុភាពនៃបុរេវិនិច្ឆ័យ" ។ ប្រទេសកាណាដា បានអនុវត្តវិធីសាស្ត្រស្រដៀងគ្នានេះដែរ ។ ករណីរបស់ *R. ទល់នឹង Zundel, (1987) 35 DLR ($4^{th}$) 338,* កថាខណ្ឌទី ១៣២, ១៤១, បានអនុញ្ញាតឲ្យអ្នកជំនាញយកឯកសារនៅសម័យកាល ដែលពួកប្រវត្តិវិទូបានពឹកផ្អែកជាប្រពៃណីមកធ្វើជាមូលដ្ឋាន ក្នុងគោលបំណងដើម្បីធ្វើការផ្តល់ជូននូវសក្ខីកម្មអំពីវត្តមាននៃហាយនភាពនោះ ។ តាមច្បាប់ប្រទេសកាណាដា អ្នកជំនាញអាចយកមតិយោបល់របស់ខ្លួនភាគខ្លះ ឬទាំងស្រុង

iv. <u>ចម្លើយមួយចំនួន អាចទទួលយកបានដោយសារវាជាភស្តុតាងនាំមុខ (Lead Evidence)</u>

៣៥. ចម្លើយទាំងនេះដែលមាននៅក្នុងចម្លើយសារភាព យ៉ាងហោចណាស់គួរតែអាចទទួលយកដាក់បញ្ចូលទៅក្នុងសំណុំរឿងបាន សម្រាប់គោលបំណងដែលមានកំរិត ធ្វើជាភស្តុតាងនាំមុខ (Lead Evidence) នៅក្នុងការស៊ើបសួរលើកក្រោយ ។ មាត្រា ២៣ ថ្មីនៃច្បាប់ អ.វ.ត.ក ដែលបានឆ្លុះបញ្ចាំងឡើងវិញនៅក្នុងមាត្រា ៥៥.៥ បានចែងថា៖ ស.ច.ស "អាចផ្អែកទៅលើមូលដ្ឋាននៃព័ត៌មាន ដែលទទួលបានពីស្ថាប័ននានា រួមមាន រដ្ឋាភិបាល ស្ថាប័ននានារបស់អង្គការសហប្រជាជាតិ ឬអង្គការក្រៅរដ្ឋាភិបាលជាដើម" ។ មាត្រានេះ បានចែងបន្តទៀតថា៖ ស.ច.ស "មានអំណាចក្នុងការសួរចម្លើយជនសង្ស័យ ជនរងគ្រោះ និងស្តាប់ចម្លើយសាក្សី និងប្រមូលភស្តុតាងដោយអនុវត្តតាមនីតិវិធីជាធរមាន" ។

៣៦. វិធាន ៥៥.៥ នៃវិធានផ្ទៃក្នុង បានចែងថា "នៅក្នុងការដឹកនាំកិច្ចស៊ើបសួរ ក.ស.ច.ស អាចចាត់វិធានការណ៍ស៊ើបសួរដែលនាំទៅរកការបង្ហាញការពិត" ។ ដើម្បីបំពេញកិច្ចស៊ើបសួរ ក.ស.ច.ស អាច*ក្នុងចំណោមកិច្ចការដទៃទៀតជាច្រើន* "កោះហៅ និងសួរចម្លើយជនសង្ស័យ និងជនត្រូវចោទ ស្តាប់ចម្លើយជនរងគ្រោះ និងសាក្សី និងកត់ត្រាទុកនូវចម្លើយរបស់ពួកគេ ប្រមូលវត្ថុតាង ស្វែងរកយោបល់ពីអ្នកជំនាញ និងដឹកនាំការស៊ើបសួរចុះដល់ទីកន្លែងកើតហេតុ" ។ ដោយមានការព្រមានឲ្យដឹងជាមុនថា ក.ស.ច.សត្រូវដឹកនាំកិច្ចស៊ើបសួរដោយអនាគតិ នៅក្នុងពេលប្រមូលភស្តុតាង ទោះបីជាភស្តុតាងដាក់បន្ទុក ឬភស្តុតាងដោះបន្ទុកក៏ដោយ" ពុំមានបទបញ្ញត្តិណាមួយនៅក្នុងវិធានផ្ទៃក្នុង ឬនៅក្នុងច្បាប់អ.វ.ត.ក រារាំង ក.ស.ច.ស មិនឲ្យពឹងផ្អែកលើព័ត៌មានណាមួយពាក់ព័ន្ធនឹងមន្ទីរស-២១ ដែលស្ថិតនៅក្រោមការចាត់ចែងរបស់ខ្លួនឡើយ ក្នុងគោលបំណងដើម្បីធ្វើការស៊ើបសួរនាំផ្លោះទៅរកការនាំមុខគេផ្សេងៗទៀតដែលព្យាយាមដើម្បីស្វែងរកការពិតនោះទេ ។

---

អំពីចម្លើយនានាដែលមិនត្រូវបានទទួលយក ធ្វើជាភស្តុតាងមកធ្វើជាមូលដ្ឋានបាន ដើម្បីបន្តទៅធ្វើការថ្លឹងថ្លែងឲ្យបានត្រឹមត្រូវ សម្រាប់ជាការព្រមព្រៀងឲ្យត្រូវរ៉ូវគ្នាជាមួយនឹងមតិ យោបល់របស់ខ្លួន, គឺមិនមែនជាភាពដែលអាចទទួលយកបាននៃមតិយោបល់របស់ខ្លួននោះទេ ។ *សូមមើល* ឧទាហរណ៍៖ *City of St. John ទល់នឹង Irving Oil Ltd.* (1966), 58 DLR (2d) 404, ទំព័រទី ១២ ។

៣៧. នៅដំណាក់កាលនេះ ភស្តុតាងនេះអាចត្រូវបានប្រើប្រាស់ធ្វើជាមូលដ្ឋាន សម្រាប់ធ្វើការស៊ើបអង្កេតបន្ថែម និងថាតើវាមានលក្ខណៈពេញលេញសម្រាប់ធ្វើជាភស្តុតាង សម្រាប់តុលាការដែលអាចត្រូវបានកំណត់សម្រេចទៅលើអង្គសេចក្តីនៃរឿងក្តីពិសេសមួយបានដែរឬទេ ។ ការហាមឃាត់ក្នុងការប្រើប្រាស់ ភស្តុតាងនៅដំណាក់កាលនេះមុខជានឹងជ្រៀតជ្រែកទៅដល់សមត្ថភាពរបស់រដ្ឋក្នុងការស៊ើបអង្កេត និងក្នុងការផ្តន្ទាទោសនូវរាល់អំពើធ្វើទារុណកម្មដូចដែលបានតម្រូវដោយអនុសញ្ញា CAT ត្រង់មាត្រា ១២[49] ។

**ឃ. ចំណារនៅលើចម្លើយសារភាពនិងជីវប្រវត្តិ គឺជាភស្តុតាងដែលអាចទទួលយកបាន ដោយមិនស្ថិតនៅក្រោមការពិនិត្យពិច័យតាមមាត្រា ១៥ នៃអនុសញ្ញា CAT ទេ**

១. <u>ចំណារនៅលើចម្លើយសារភាព</u>

៣៨. ចំណារទាំងឡាយនៅលើចម្លើយសារភាពនានា គឺជាចម្លើយដែលអាចទទួលយកបាន និងអាចជឿទុកចិត្តបានផងដែរ ដោយសារវាមិនមែនជាចម្លើយដែលបានមកតាមរយៈការធ្វើទារុណកម្មទេ។ ផ្ទុយមកវិញ គឺជាចម្លើយដែលត្រូវបានធ្វើឡើងដោយបុគ្គលិករបស់មន្ទីរស-២១ ដែល ជាអ្នកដឹកនាំការធ្វើទារុណកម្ម ដែលជាញឹកញាប់ផ្ទុះបញ្ជាំងឲ្យឃើញពីឈ្មោះរបស់បុគ្គលនានាដែលត្រូវបានគេធ្វើទំនាក់ទំនងអំពីចម្លើយសារភាព ឬពីបុគ្គលណាម្នាក់ដែលមានឈ្មោះនៅក្នុងចម្លើយសារភាពដែលត្រូវបានគេចាប់ខ្លួន និង/ឬ សម្លាប់ចោល ។ ដោយសារតែចម្លើយទាំងនេះ មិនមែនធ្វើឡើងដោយបុគ្គលដែលត្រូវគេធ្វើទារុណកម្មនោះ គឺគ្មានមូលដ្ឋានណានៅក្រោមមាត្រា១៥ ឬក្រោមបទប្បញ្ញត្តិណាមួយផ្សេងទៀត ដើម្បីច្រានចោល នូវសក្ខីកម្មទាំងនេះបានទេ ។

---

[49] មាត្រា ១២ នៃអនុសញ្ញា CAT ចែងថា៖ "[ភាគីនីមួយៗ] ត្រូវធានា... ការស៊ើបអង្កេតដ៏ឆាប់រហ័សនិងមិនលំអៀង នៅពេលណាដែលមានហេតុផលសមស្របនាំឲ្យជឿបានថា អំពើនៃការធ្វើទារុណកម្មមួយត្រូវបានប្រព្រឹត្តឡើង នៅក្នុងប្រទេសណាមួយដែលស្ថិតក្រោមយុត្តាធិការរបស់ខ្លួន" ។

៣៩. ចំណារ ដែលអមជាមួយនឹងចម្លើយសារភាពទាំងឡាយ ត្រូវតែបានទទួលយក ពីព្រោះចម្លើយសារភាពទាំងនោះត្រូវបានគេទទួលយកយ៉ាងហោចណាស់ ក៏ដើម្បីបង្ហាញឱ្យឃើញថា ការធ្វើទារុណកម្មបានកើតឡើង ដូចបានអនុញ្ញាតតាមមាត្រា ១៥ នៃអនុសញ្ញា CAT ។ អ្វីដែលសំខាន់បំផុត ចម្លើយសារភាពគួរតែត្រូវបានគេទទួលយក ដើម្បីផ្តល់ជាបរិបទសម្រាប់ចំណារហើយដែលផល់វេនរបស់ខ្លួនឯង ចំណារនេះឆ្លុះបញ្ចាំងអំពីការបានដឹង និង អំពីស្ថានភាពស្មារតីរបស់អ្នកប្រព្រឹត្តបទល្មើស និងជនត្រូវចោទ ទាក់ទងអំពីព័ត៌មានដែលមាននៅក្នុងចម្លើយសារភាពទាំងឡាយ ដែលត្រូវបានគេធ្វើចំណារនៅលើនោះ ។ បើមិនដូច្នោះទេ ចំណារដែលដាច់តែឯង មិនអាចឱ្យគេយល់បានឡើយ ។

២. <u>ជីវប្រវត្តិ</u>

៤០. ព័ត៌មានអំពីប្រវត្តិរូបរបស់អ្នកជាប់ឃុំឃាំងដែលអាចជឿទុកចិត្តបាន និងដែលអាចទទួលយកបាន ត្រូវបានរកឃើញមាននៅក្នុងឯកសារដែលចុះបញ្ជី នៅពេលដែលពួកគេបាន ទៅដល់មន្ទីរស-២១ ។ ឯកសារនានាដែលចុះបញ្ជីនោះ មានរួមបញ្ចូលនូវព័ត៌មានផ្សេងៗ ដូចជា៖ ឈ្មោះ អាយុ ទីកន្លែងរស់នៅ ការងារនៅមុននិងក្រោយបដិវត្តន៍ ពេលវេលា និង ទីកន្លែងនៃការចាប់ខ្លួនជាដើម ទាំងអស់នេះមិនមានការប៉ះពាល់ដល់មាត្រា ១៥ នៃអនុសញ្ញា CAT ទេ ព្រោះថាព័ត៌មានទាំងនេះមិនត្រូវបានប្រមូលតាមរយៈការធ្វើទារុណកម្មទេ[50] ក៏ប៉ុន្តែគ្រាន់តែត្រូវបានប្រមូលនៅពេលបញ្ចូលទៅក្នុងមន្ទីរស-២១ តែប៉ុណ្ណោះ។

## ៤. សេចក្តីសន្និដ្ឋាន

៤១. ដើម្បីផ្តល់នូវនិយមន័យដល់គោលការណ៍ដែលមាននៅក្នុងអនុសញ្ញា CAT និងដើម្បីធានាថាអ្នកដែលទទួលខុសត្រូវក្នុងការធ្វើទារុណកម្មលើជនរងគ្រោះនៅមន្ទីរស-២១ ត្រូវបានដាក់ឱ្យ

[50] ហើយទាំងឯកសារដែលបានចុះបញ្ជីទាំងនេះ ក៏មិនត្រូវបានគេចោទថា ត្រូវបានប្រមូលតាមរយៈការធ្វើទារុណកម្មដែរ ។

ទទួលខុសត្រូវ ទោះបីជាក្រោយរយៈពេលចំនួន ៣០ ឆ្នាំហើយក៏ដោយ ។ ពាក្យពេចន៍ផ្ទាល់របស់ជនរងគ្រោះ ត្រូវតែបានអនុញ្ញាតឱ្យនិយាយចេញ ដើម្បីឱ្យគេបានដឹងឮ ។

៤២. ដើម្បីធានានូវអំពីបញ្ហាទាំងនោះ និងអាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សហព្រះរាជអាជ្ញា ស្នើដល់ សហចៅក្រមស៊ើបអង្កេត បដិសេធសំណើរបស់សហមេធាវីការពារក្តីទាំងស្រុង និងសុំឱ្យរក្សាទុកដដែលនូវភស្តុតាងទាក់ទងនឹងការធ្វើទារុណកម្មនៅក្នុងសំណុំរឿងលេខ ០០២ ដែលត្រូវបានប្រឆាំងជំទាស់ និងសុំឱ្យដាក់បញ្ចូលទៅក្នុង សំណុំរឿងលេខ ០០២ នូវភស្តុតាងដែលទាក់ទងនឹងការធ្វើទារុណកម្មស្រដៀងគ្នានេះណាមួយដែលត្រូវទៅតាមលក្ខណៈវិនិច្ឆ័យដូចដែលបានរៀបរាប់ខាងលើ ។

ធ្វើនៅភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា
នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ២០០៩
**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង លោក Robert PETIT